អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jan-2017, 15:23
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី៤៨៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ែន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរលក្ស័

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក សេង លាង | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ប៊ិត បឿន (2-TCW-953) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី ប៊ិត ឡឿន** (2-TCW-953)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ..................... ទំព័រ ៤
សួរដោយលោក វីល្លៀម ស្មីតផ្តើមពី ..................... ទំព័រ ៧
សួរដោយលោក សេង លាង ផ្តើមពី ..................... ទំព័រ ២៨
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី ..................... ទំព័រ ៣៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-953។ ហើយសាក្សីរូបនេះ តាមសំណើសុំរបស់គាត់ គឺអង្គជំនុំជម្រះផ្តល់ឲ្យតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញនូវមេធាវីប្រឹក្សាសាក្សី គឺលោកស្រី សុក សុជាតា។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នេះនៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCW-953។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង លោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។ ហើយសាក្សីមានមេធាវីប្រឹក្សា លោកស្រី សុក សុជាតា។ សូមអរគុណលោកប្រធាន។

[០៩:០៦:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់

ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ បានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឱ្យមានប្រសិទ្ធិភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ ក្នុងបន្ទប់សវនាការនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់នៃសិទ្ធិ នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួន ក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាង ក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលាលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅ អ.វ.ត.ក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦។ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា ថានៅថ្ងៃនេះ ថាមានអាការឈឺចង្កេះរ៉ាំរ៉ៃ ឈឺកាន់តែខ្លាំងនៅពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សូមឱ្យអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយ ស្ថិតក្រោមសាលសវនាការនេះ។

[០៩:០៧:៤៦]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះ អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជាអាចចូលរួម និងតាមដាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ហើយថ្ងៃនេះ ក៏មានអង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចផ្ទាល់មាត់មួយ ដែលពាក់ព័ន្ធនឹងដំណើរការនៃការស្តាប់សក្ខីកម្មសាក្សី 2-TCW-953 គឺសេចក្តីសម្រេចពីការទទួលយកចម្លើយពីមុនៗ និងខ្សែអាត់សំឡេងនៃការស្តាប់សក្ខីកម្មសាក្សីរូបនេះ។

អនុលោមតាមសេចក្តីណែនាំថ្មីដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្កើតឡើង សម្រាប់

ការស្នើសុំដាក់បង្ហាញឯកសារពីសំណុំរឿង០០៣ និង០០៤ កាលពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ បានផ្ញើឯកសារ D114/183 ដែលជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី 2-TCW-953 មកអង្គជំនុំជម្រះសាលាដំបូង និងភាគីផ្សេងទៀត តាមរយៈអ៊ីម៉ែល។

[០៩:០៩:១០]

សាក្សីរូបនេះ ត្រូវបានកំណត់ពេលឲ្យមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២ នៅក្នុងប្រធានបទសវនាការស្តីពីតួនាទីរបស់ជនជាប់ចោទ។ បន្ទាប់មកទៀត សហព្រះរាជអាជ្ញាអន្តរជាតិក៏បានផ្ញើខ្សែអាត់សំឡេងនៃការស្តាប់សក្ខីកម្មនេះ ឯកសារ D114/183R ជូនភាគីនិងអង្គជំនុំជម្រះផងដែរ។ នៅថ្ងៃទី០៧ ខែវិច្ឆិកា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអនុញ្ញាតតាមរយៈអ៊ីម៉ែល ឲ្យដាក់បង្ហាញឯកសារ D114/183 និង D114/183R ដល់ភាគីក្នុងសំណុំរឿង០០២។ ហើយបន្ទាប់មក បានចេញសេចក្តីសម្រេចជាផ្លូវការ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ (ឯកសារ D100/40)។

អង្គជំនុំជម្រះរំឭកអំពីការរំឭកអំពីការអនុវត្តរបស់ខ្លួន ក្នុងការទទួលយកចម្លើយពីមុនៗទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីដែលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ហើយថាការដែលអង្គជំនុំជម្រះ និងភាគីអាចចូលពិនិត្យចម្លើយទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលនឹងត្រូវផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២/០២ គឺជាប្រយោជន៍នៃការស្វែងរកការពិត (ឯកសារ E363/3 កថាខណ្ឌ២៥)។ ហេតុនេះតាមផ្លូចផ្តើមរបស់ខ្លួន អង្គជំនុំជម្រះសម្រេចទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយពីមុនរបស់សាក្សី 2-TCW-953 គឺឯកសារ D114/183 ហើយដាក់លេខឯកសារជាឯកសារ E3/10727។

[០៩:១១:១០]

អង្គជំនុំជម្រះក៏រំឭកផងដែរ អំពីសេចក្តីសម្រេចរបស់ខ្លួននាពេលថ្មីៗនេះថា ជាទូទៅអង្គជំនុំជម្រះនឹងមិនទទួលយករាល់ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយទាំងអស់មកធ្វើជាភស្តុតាងនោះទេ អង្គជំនុំជម្រះអាចទទួលយកជាភស្តុតាងនូវផ្នែកពាក់ព័ន្ធជាក់លាក់នៃខ្សែអាត់សំឡេង នៅពេលដែលភាគីចង្អុលបង្ហាញចំណុចមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់សំឡេង និងកំណត់ហេតុនៃការស្តាប់ចម្លើយ ឯកសារ E441/2 កថាខណ្ឌ១៧។ ដោយសារពុំមានការចង្អុលបង្ហាញចំណុចមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់សំឡេង និងកំណត់ហេតុនៃការស្តាប់សក្ខីកម្មសាក្សី 2-TCW-953 អង្គជំនុំជម្រះនឹងមិនទទួលយកឯកសារ D114/183R ជាភស្តុតាងនៅដំណាក់កាលនេះទេ។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីសាក្សី។ តើលោកស្រីឈ្មោះអី?

**លោកស្រី ប៊ិត ឿន៖**

**ឆ៖** នាងខ្ញុំឈ្មោះ ប៊ិត ឿន ហៅ ណា។

**ស៖** បាទ អរគុណ។ លោកស្រីៗ ប៊ិត ឿន តើលោកស្រីកើតនៅថ្ងៃ ខែ ឆ្នាំណា?

**ឆ៖** នៅឆ្នាំ១៩៥០។

**ស៖** ទីកន្លែងកំណើតរបស់លោកស្រីនៅទីកន្លែងណាដែរ?

**ឆ៖** នៅភូមិដើមឫស ឃុំដើមឫស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

[០៩:១៥:៤២]

**ស៖** បាទ អរគុណ។ ចុះទីលំនៅសព្វថ្ងៃនេះ តើលោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** នៅកន្លែងដដែល។

**ស៖** លោកស្រីប្រកបមុខរបរអ្វីដែរ?

**ឆ៖** ធ្វើស្រែ។

**ស៖** លោកស្រីប្រកបមុខរបរអ្វីដែរ?

**ឆ៖** ធ្វើស្រែ។

**ស៖** ឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកស្រីឈ្មោះអី?

**ឆ៖** ឪពុកឈ្មោះ ប៊ិត ប៊ូ។ ម្តាយឈ្មោះ ពៅ អាយ។

**ស៖** បាទអរគុណ។ ហើយចុះប្តីរបស់លោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ឈ្មោះ ឡុង ប៊ុនធូន។ អត់មានកូនទេ។

**ស៖** បាទ អរគុណ។ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកស្រីដឹង គឺថាលោកស្រីមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយ

នឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន ក៏ដូចជាបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ តើពិតមែនដែរឬទេ?

**ឆ៖** ចាស ពិតមែន។

[០៩:១៦:១១]

**ស៖** ហើយលោកស្រីបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែករួចហើយឬនៅ មុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** នាងខ្ញុំបានធ្វើរួចហើយ។

**ស៖** បាទ អរគុណ។ ហើយតទៅនេះយើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកស្រីជាសាក្សីនៅចំពោះអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោកស្រី ប៊ិត បឿន ក្នុងឋានៈលោកស្រីជាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬក៏សូមឱ្យលោកស្រីធ្វើការរៀបរាប់ដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងឋានៈជាសាក្សី លោកស្រីត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី លើកលែងតែសំណួរណាដែលនាំឱ្យចម្លើយតប ឬការធ្វើអត្ថាធិប្បាយរបស់លោកស្រីនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរួចហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈជាសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកស្រីបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី។

ហើយតើលោកស្រីធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេកន្លងមក? ហើយប្រសិនបើធ្វើ ១ប៉ុន្មានដង? ធ្វើនៅទីកន្លែងណា?

[០៩:១៧:៤៩]

**ឆ៖** បានធ្វើបីដង ជាមួយ ធ្វើនៅដើមឫសពីរដង និងធ្វើនៅផ្សារថ្មីមួយដង។

**ស៖** លោកស្រីចាំទេថា ខាង១ណាគេអ្នកធ្វើកិច្ចសម្ភាសន៍ជាមួយនឹងលោកស្រីនោះ? ខាងតុលាការខ្មែរក្រហមនេះ ឬក៏ខាងផ្សេងទៀត ដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជា លោកស្រីចាំទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខាងមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** ចុះជាមួយខាងអ្នកស៊ើបអង្កេតនៃសាលាក្តី អ.វ.ត.ក នេះ គេហៅថាសាលាក្តីខ្មែរក្រហម បើយើងនិយាយកាត់ធម្មតា តើមានអ្នកណាដែលធ្លាប់ទៅធ្វើការសាកសួរស្តាប់សក្ខីកម្មរបស់លោកស្រីដែរឬទេ?

**ឆ៖** ខាងខ្មែរក្រហម ខ្ញុំអត់យល់។

**ស៖** ខាងតុលាការនេះ ខាងតុលាការ នេះហៅតុលាការខ្មែរក្រហម បើយើងបើហៅតុលាការ គេហៅថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ពាក្យនេះលោលោកស្រីពិបាកស្តាប់ អ៊ីចឹងយើងគ្រាន់និយាយដើម្បីឱ្យសម្រាយឱ្យលោកស្រីយល់ថា ជាទូទៅគេកាត់ គេហៅកាត់ថា តុលាការជំនុំជម្រះមេដឹកនាំខ្មែរក្រហម ឬក៏តុលាការខ្មែរក្រហម វានិយាយកាត់អ៊ីចឹង។ ថាតើមានធ្វើ មានខាងណាបុគ្គលិកខាងណាបានទៅធ្លាប់ធ្វើកិច្ចសម្ភាសន៍ជាមួយនឹងលោកស្រីដែរឬទេ?

**ឆ៖** លោកអង្គការខ្មែរក្រហមហ្នឹងទៅដែរ។

**ស៖** ទៅពីអង្កាល់ដែរលោកស្រី លោកស្រីចាំទេ? ហើយធ្វើៗស្តាប់ចម្លើយរបស់លោកស្រីហ្នឹងពីណាមក លោកស្រីចាំទេ?

[០៩:២០:០០]

**ឆ៖** យូរដែរ ខ្ញុំមិនសូវចាំដែរ។

**ស៖** ហើយនឹងមុននឹងចូលមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីបានពិនិត្យមើល ឬបានអាន ឬក៏ស្តាប់ការអានពីបុគ្គលណាមួយឱ្យលោកស្រីស្តាប់អំពីកំណត់ហេតុដែលលោកស្រីបានផ្តល់សក្ខីកម្មអង្កាល់ពីពេលមុននោះដែរឬទេ ដើម្បីរំឭកការចងចាំរបស់លោកស្រី?

**ឆ៖** នាងខ្ញុំបានអាន។

**ស៖** អរគុណ។ ហើយតាមសមត្ថភាពដែលលោកស្រីអាចដឹង តើលោកស្រីអាចបញ្ជាក់បានដែរទេថា កំណត់ហេតុដែលលោកស្រីបានអានដើម្បីរំឭកការចងចាំហ្នឹងវាត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលលោកស្រីបានផ្តល់កិច្ចសម្ភាសន៍នាពេលមុននោះដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

**ប្រធានអង្គជំនុំ៖**

បាទ លោកស្រី ប៊ិត បឿន ហើយលោកបានទទួលជំនួយមេធាវីប្រឹក្សាសាក្សីតាមរយៈ ដែលអង្គ

ជំនុំជម្រះផ្ដល់ឲ្យតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញរួចហើយ តាមសំណើររបស់លោកស្រី គឺលោកស្រី សុក សុជាតា។

ហើយក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។ សហព្រះរាជអាជ្ញា រួមទាំងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:២២:០២]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រី ចៅក្រម ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី ខ្ញុំឈ្មោះ វីល្លៀម ស្មីត ជាអ្នកតំណាងឲ្យការិយាល័យសហព្រះរាជអាជ្ញាដែលត្រូវសួរលោកស្រីថ្ងៃនេះ នូវអ្វីដែលបានកើតឡើងចំពោះលោកស្រីក្នុងអំឡុងរបបខ្មែរក្រហម ហើយនិងថា តើមានអ្វីកើតឡើងចំពោះលោកស្រីដែរ<ពីពេលមុន,> ហេតុអ្វីបានជាលោកស្រីចូលរួមជាមួយនឹងចលនាខ្មែរក្រហម។ ប្រសិនបើលោកស្រីយល់សំណួរមិនបានច្បាស់ សូមលោកស្រីថាលោកស្រី<>មិនបានច្បាស់ទេ <ក៏ប៉ុន្តែនៅត្រង់ចំណុចដែលលោកស្រីច្បាស់ សូម>លោកស្រីផ្ដល់ចម្លើយឲ្យបានច្បាស់លាស់។ អម្បាញ់មិញនេះលោកស្រីបានជម្រាបទៅលោកប្រធានថា លោកស្រីកើតនៅស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ហើយលោកស្រីក៏បានឆ្លើយថា លោកស្រីកើតនៅក្នុងឆ្នាំ១៩៥០។ តើលោកស្រីអាចជម្រាបជូនតុលាការបានទេ ថាលោកស្រីនេះបានចូលរួមជាមួយចលនាបដិវត្តន៍ ឬក៏ចលនាខ្មែរក្រហមនេះនៅពេលណាដែរ?

[០៩:២៣:២៧]

**លោកស្រី ប៊ិត ហឿន៖**

**ឆ៖** ខ្ញុំធ្លាប់បានចូលរួមបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧១។

**ស៖** តើហេតុអ្វីបានជាលោកស្រីចូលរួមជាមួយចលនាបដិវត្តន៍? ហើយតើអ្នកណាដែលជាអ្នកឧទ្ទេសនាមឲ្យលោកស្រីចូលរួមនោះ?

ឆ៖ ជំនាន់ហ្នឹងមានអ្នកបដិវត្តន៍គេមកឃោសនាឲ្យយើងចូលរួមប្រឆាំង ចូលរួមធ្វើបដិវត្តន៍ ប្រឆាំងនឹងរបប ប៉ុល ពត អ៊្នា នឹងរបប លន់ នល់ សូមទោស របប លន់ នល់។

ស៖ នៅពេលដែលគេណែនាំឲ្យលោកស្រីចូលរួមចលនាបដិវត្តន៍ តើគេចាត់តាំងឲ្យលោកស្រីធ្វើអ្វី <នៅពេលដំបូង>? តើពេលដែលគេណែនាំឲ្យលោកស្រីចូលរួមហ្នឹង លោកស្រីទៅរស់នៅ ឬក៏ទៅស្នាក់នៅឆ្ងាយពីទីកន្លែងកំណើតឬ?

ឆ៖ នៅពេលដែលខ្ញុំចូលរួមហ្នឹង គេបញ្ជូនខ្ញុំឲ្យទៅខេត្តកំពង់ឆ្នាំង។

ស៖ នៅពេលលោកស្រីទៅដល់ខេត្តកំពង់ឆ្នាំង តើលោកស្រីធ្វើអ្វី? តើគេមានចាត់តាំងឲ្យលោកស្រីចូលធ្វើការជាមួយនឹងកងណាមួយដែរឬទេ? ហើយបើយ៉ាងដូច្នេះ តើគេឲ្យលោកស្រី ធ្វើកិច្ចការអ្វីខ្លះដែរ?

ឆ៖ ដំបូងគេយកទៅធ្វើនឹងផ្ទះប្រជាជន ឲ្យជួយធ្វើស្រែប្រជាជន។

ស៖ តើលោកស្រីចាកចេញពីស្រុកភូមិហ្នឹង ចាកចេញដោយខ្លួនឯង ឬក៏<លោកស្រីចេញទៅជាមួយប្រជាជនផ្សេងទៀតដែលមក>ពីភូមិហ្នឹងដើម្បីទៅធ្វើស្រែនោះ?

ឆ៖ ជំនាន់ហ្នឹងគឺចលនាតស៊ូគេបំផុសឲ្យយើងទៅចូលរួមចលនាតស៊ូជាមួយគេ។

[០៩:២៦:២៦]

ស៖ ក្រោយពេលលោកស្រីទៅធ្វើស្រែនៅទីនោះ តើគេក្រៅពីហ្នឹង គេមានចាត់តាំងឲ្យលោកស្រីធ្វើអ្វីផ្សេងទៀតដែរ?

ឆ៖ ជួយធ្វើស្រែហ្នឹងមួយរយៈទៅ គេក៏ចាត់តាំងឲ្យទៅនៅមន្ទីរពេទ្យ២៨ មន្ទីរពេទ្យស្លថ្នាំ។

ស៖ ហើយនៅឯមន្ទីរពេទ្យ២៨ហ្នឹង លោកស្រីធ្វើអ្វី?

ឆ៖ គេឲ្យពួកខ្ញុំជីកឫសឈើណាដែលត្រូវយកមកស្លថ្នាំ។

ស៖ ហើយគេធ្វើថ្នាំហ្នឹង គេយកថ្នាំនេះទៅប្រើប្រាស់ដើម្បីអ្វីដែរ?

ឆ៖ ថ្នាំ មានថ្នាំកែរោគគ្រុន កែរោគរាកអ៊ីចឹងទៅ ចង់ភ្លេចមើល។

ស៖ ក្រោយពេលលោកស្រី បន្ទាប់ពីលោកស្រីធ្វើការនៅមន្ទីរពេទ្យនៅឯកំពង់ឆ្នាំងនោះ តើគេឲ្យលោកស្រីធ្វើអ្វីទៀតដែរ?

ឆ៖ អត់មានឲ្យធ្វើអីទេ ឲ្យតែដើរជីកឫសឈើហ្នឹង។

ស៖ ក្រោយពេលលោកស្រីឈប់ធ្វើការនៅមន្ទីរពេទ្យ តើគេចាត់តាំងឲ្យលោកស្រីទៅកន្លែង

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ណាទៀតបន្ទាប់មក?

**ផ៖** ឲ្យទៅធ្វើស្រែនៅថ្មយោង។

**ស៖** តើមានពេលណាមួយ គេប្រាប់ឲ្យលោកស្រីចាកចេញពីខេត្តកំពង់ឆ្នាំង ដើម្បីចូលរួមប្រយុទ្ធជាមួយនឹងទាហាន លន់ នល់ ដែរឬទេ?

[០៩:២៩:១៩]

**ផ៖** នៅឆ្នាំ១៩៧៣ គេក៏បញ្ជូនពួកខ្ញុំឲ្យមកតំបន់១៥។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រី ឆ្លើយជូនមន្ត្រីស៊ើបអង្កេតរបស់តុលាការយើងនេះ គឺត្រង់ចម្លើយ៤៦ គឺឯកសារ E3/10721 លោកស្រីបានឆ្លើយថា លោកស្រីត្រូវបានគេបញ្ជូនទៅតំបន់២៥ នៅតំបន់កប់ស្រូវ នៅជិតភ្នំប្រសិទ្ធ។ តើចំណុចនេះ វាជួយឲ្យលោកស្រីនឹកឃើញទេ?

**ផ៖** ចាស ខ្ញុំនឹកឃើញ។

**ស៖** នៅពេលដែលគេបញ្ជូនលោកស្រីទៅតំបន់២៥ នៅពេលនោះ តើលោកស្រីបានចូលរួមជាមួយនឹងកងទ័ពដែរឬទេ?

**ផ៖** ខ្ញុំបានចូលរួមក្នុងកងទ័ពដែរ នៅក្នុងកងវរសេនាតូច២២៩។

**ស៖** នៅពេលលោកស្រីមកដល់កប់ស្រូវ តើគេចាត់តាំងឲ្យលោកស្រីធ្វើអ្វី? តើគេចាត់តាំងឲ្យលោកស្រីចូលរួមប្រយុទ្ធ ឬក៏គេគ្រាន់តែចាត់តាំងលោកស្រីហ្នឹង ឲ្យជួយទៅដល់ពួកកងទ័ពប្រយុទ្ធទាំងនោះ ឬក៏ឲ្យធ្វើអ្វីផ្សេង?

**ផ៖** នៅពេលហ្នឹង គេចាត់ឲ្យខ្ញុំនៅកាន់កាំភ្លើងអា៨០ ចូលក្នុងក្រុម៨០។

**ស៖** តើគេមានចាត់តាំងឲ្យលោកស្រីសែងកងទ័ពដែលត្រូវរបួសដែរឬទេ?

**ផ៖** ចាស ដែលដែរ។

[០៩:៣២:០៧]

**ស៖** នៅពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសា ១៩៧៥ តើអង្គភាពលោកស្រីធ្វើអ្វីដែរ?

**ផ៖** នៅឆ្នាំបែក ១៧ មេសា ៧៥ អង្គភាពខ្ញុំគេឲ្យបញ្ជូនគ្រាប់ ជញ្ជូនគ្រាប់កងទ័ព។

**ស៖** នៅពេលលោក<ស្រី>ធ្វើការជាមួយនឹងកងទ័ពខ្មែរក្រហមនៅកប់ស្រូវនេះ តើលោកស្រីគ្រាន់តែជាកងទ័ពតូចតាចហ្នឹងធម្មតា ឬក៏លោកស្រីមានតួនាទីក្នុងការបញ្ជាកងទ័ពណាមួយដែរ?

**ឆ៖** ខ្ញុំជាកងទ័ពតូចតាចធម្មតា ត្រឹមកងអនុសេនាតូច ក-៣ ប៉ុណ្ណឹង។

**ស៖** កងវរសេនាតូចលេខ២២៩ របស់លោកស្រីហ្នឹង កងទ័ពទាំងអស់នៅក្នុងកងវរសេនាតូចនេះ<មានប្រុស និងស្រី ឬ>ទាំងអស់សុទ្ធតែជាស្រីតែម្តង ឬក៏ជាកងទ័ពប្រុសៗទាំងអស់តែម្តង?

**ឆ៖** ចាស គឺសុទ្ធតែស្រី។

**ស៖** តើគេមានបានបញ្ជូនលោកស្រីឱ្យមកភ្នំពេញដែរឬទេ ក្រោយពីការឈប់ប្រយុទ្ធគ្នាជាមួយនឹងកងទ័ព លន់ នល់ ទៅ?

**ឆ៖** ក្រោយពីការឈប់ប្រយុទ្ធជាមួយនឹងកងទ័ព លន់ នល់ ទៅ កងនាងខ្ញុំ ត្រូវមកភ្នំពេញនៅប្រហែលជាម៉ោងប្រាំពីរយប់ គឺគេជម្លៀសប្រជាជនផុតអស់ហើយ។

**ស៖** តើគេប្រគល់ភារកិច្ចឱ្យលោកស្រីធ្វើអ្វីដែរ ទៅនៅកន្លែងណាដែរ ក្រោយពេលលោកស្រីមកដល់ទីក្រុងភ្នំពេញ?

**ឆ៖** មកដល់ៗភ្នំពេញដំបូង គេបញ្ជូននាងខ្ញុំយកមកដាក់នៅស្តាត។ ហើយនៅស្តាតហ្នឹង ឱ្យធ្វើស្រែនៅសំរោងអណ្តែត ខាងលិចពោធិ៍ចិនតុងនេះ។ ហើយក្នុងនុំង ក៏មានបញ្ជូនធ្វើស្រែនៅពោធិ៍ចិនតុងមួយរយៈ ក៏បញ្ជូននាងខ្ញុំ តែនៅក្នុងស្តាតដដែលទេ ក៏បញ្ជូនឱ្យទៅដេរនៅគីឡូម៉ែត្រលេខ៦ ជិតហាងសាំង សាលា កន្លែងសាលាដៃដែកនោះ។

[០៩:៣៤:៥៨]

**ស៖** នៅពេលហ្នឹង តើលោកស្រី<ដេរខោអាវឱ្យ>អ្នកណាដែរ?

**ឆ៖** នៅពេលហ្នឹង អត់មានជិតដិតជាមួយអ្នកណាទេ នៅតែក្នុងកងស្រីៗហ្នឹង។ ហើយតែមកដល់ភ្នំពេញហ្នឹង គេបញ្ចូលនាងខ្ញុំនៅក្នុងកងពល៨០១ សេនាធិការ។

**ស៖** តើលោកស្រីស្នាក់នៅឯស្តាតអូឡាំពិក រហូតដល់សម្តេច នរោត្តម សីហនុ យាងត្រឡប់មកប្រទេសកម្ពុជាវិញ អ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** នាងខ្ញុំនៅស្តាតហ្នឹងរហូត។ ហើយទៅដេរនៅ ដេរខោអាវកងទ័ពនោះផង ដើម្បីយកខោអាវហ្នឹងមកឧបត្ថម្ភកងទ័ព ហើយនិងដេរខោអាវសម្រាប់ទទួលសម្តេចតាផង។

**ស៖** ហើយបន្ទាប់មក តើលោកស្រីឈប់ស្នាក់នៅស្តាតអូឡាំពិក ហើយទៅចាប់ផ្តើមធ្វើការនៅ<ទួល>ស្វាយព្រៃ <និង>នៅម៉ុំនៅទួលទំពូង អ៊ីចឹងឬ?

**ឆ៖** ចាស បន្ទាប់ពីទទួលសម្តេចតាហើយ ពួកខ្ញុំមកនៅម៉ុំទួលស្វាយព្រៃ ជិតស្ថានទូតចិនហ្នឹង

ដើម្បីនៅកន្លែងហ្នឹងដេរដែរ កាត់ដេរដដែល ប៉ុន្តែទៅធ្វើស្រែនៅម្តុំអូរបែកក្អមជិតស្ទឹងមានជ័យផង។

**ស៖** អ្នកប្រវត្តិសាស្ត្រមួយរូប ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការយើងនេះ គឺបានសរសេរសៀវភៅមួយ គឺឯកសារ E3/2376, ERN 00192228 ជាភាសាអង់គ្លេស, ខ្មែរ <00191354>, បារាំង 00236947។ អ្នកប្រវត្តិសាស្ត្ររូបនេះ បានសរសេរថា៖ "សម្តេច នរោត្តម សីហនុ យាងត្រឡប់មកភ្នំពេញវិញនៅ<ថ្ងៃទី០៩> ខែកញ្ញា ឆ្នាំ១៩៧៥។" អ៊ីចឹងតើវាជួយរំឭកដល់ការចងចាំរបស់លោកស្រីបានដែរឬទេ ថាលោកស្រីចាកចេញឈប់នៅស្ពាតអូឡាំពិកហ្នឹង នៅពេលនុ៎ង នៅខែកញ្ញា ថ្ងៃទី០៩ ១៩៧៥?

[០៩:៣៩:៣១]

**ឆ៖** ខ្ញុំៗអត់យល់កន្លែងហ្នឹង។

**ស៖** តើសម្តេចព្រះ នរោត្តម សីហនុ យាងមកដល់ប្រទេសកម្ពុជាវិញ នៅពេលណា? លោកស្រីចាំថ្ងៃខែឆ្នាំ ពេលដែលព្រះអង្គយាងមកដល់ដែរឬទេ?

**ឆ៖** នាងខ្ញុំ មិនបានចាំដែរ ប៉ុន្តែគ្រាន់តែនាងខ្ញុំដែលធ្លាប់ទៅទទួល នៅព្រលានយន្តហោះ។

**ស៖** នៅពេលដែលលោកស្រីទៅធ្វើការនៅជិតស្ពានទូតចិន ទៅដេរខោអាវ ហើយក៏ទៅធ្វើស្រែផងនោះ តើលោកស្រីនៅជាមួយនឹង -- ពេលហ្នឹងនៅជាប់ជាមួយនឹងកងវរសេនាតូច២២៩ដដែល ឬក៏យ៉ាងណា?

**ឆ៖** ចាស នាងខ្ញុំនៅជាប់នឹងកងវរសេនាតូច២២៩ដដែល។

**ស៖** ហើយបន្ទាប់មក គេឲ្យលោកស្រីចាកចេញ គឺថាឈប់នៅជាមួយនឹងកងវរសេនាតូច២២៩ ហើយឲ្យលោកស្រីមកចូលធ្វើការនៅក្រសួងពាណិជ្ជកម្មវិញ អ៊ីចឹងឬ?

**ឆ៖** ចាស នៅឆ្នាំ១៩៧៧ នាងខ្ញុំត្រូវអង្គការចាត់តាំងឲ្យមកនៅក្រសួងពាណិជ្ជកម្មក្នុងប្រទេស។

[០៩:៤១:៣៥]

**ស៖** នៅក្នុងឆ្នាំ១៩៧៧ហ្នឹង នៅពេលដែលគេបញ្ជូនលោកស្រីទៅឲ្យធ្វើការជាមួយនឹងក្រសួងពាណិជ្ជកម្ម លោកស្រីនៅចាំទេ ដឹងថានៅក្នុងខែណាទេ?

**ឆ៖** នៅខែ៧។

**ស៖** នៅពេលលោកស្រីចូលរួមធ្វើការជាមួយនឹងក្រសួងពាណិជ្ជកម្ម ដំបូងគេចាត់តាំងឲ្យលោកស្រីធ្វើអ្វីដែរ?

**ឆ៖** រើសផលិតផល មានគ្រាប់កាហ្វេ គ្រាប់សណ្តែកដី បកគ រៀបគ។

**ស៖** នៅពេលដែលលោកស្រីទៅធ្វើការជាមួយនឹងក្រសួងពាណិជ្ជកម្មហ្នឹង គិតអំពីទីតាំងទីក្រុងភ្នំពេញ លោកស្រីទៅធ្វើការនៅម្តុំណាដែរ? ឬក៏នៅ<តែរស់>នៅជិតស្ពានទូតចិនហ្នឹងដដែល?

**ឆ៖** ទៅដំបូង នៅផ្សារចាស់ បន្ទាប់មកយកមកនៅ អង្គការឲ្យមកនៅវត្តទួលទំពូង។

**ស៖** នៅក្រសួងពាណិជ្ជកម្មដែលលោកស្រីស្នាក់នៅក្នុងវត្តទួលទំពូងហ្នឹង គេឲ្យលោកស្រីនៅចំណុះកងណាមួយដែរ ចំណុះឲ្យក្រសួងពាណិជ្ជកម្មនោះ?

**ឆ៖** នៅក្រសួងពាណិជ្ជកម្មហ្នឹង គេចាត់តាំងនាងខ្ញុំឲ្យធ្វើជាប្រធានផ្នែក។

**ស៖** តើនៅពេលនោះ លោកស្រីធ្វើការជាមួយនឹងមន្ទីរពាណិជ្ជកម្មក្នុងប្រទេស មែនទេ?

**ឆ៖** ចាស។

**ស៖** ចុះកង ឬក៏អង្គភាពដែលលោកស្រីជាអ្នកទទួលខុសត្រូវហ្នឹង គេហៅកងលេខប៉ុន្មាន កងឈ្មោះអីដែរ?

**ឆ៖** ចាស អត់មានលេខទេ គឺមានតែក្រសួងតែម្តង។

[០៩:៤៤:៤០]

**ស៖** នៅក្នុងចម្លើយរបស់លោកស្រីឆ្លើយជូនអ្នកស៊ើបអង្កេត គឺ១៥៣ លោកស្រីថាលោកស្រីជាប្រធានផ្នែក<រើសផលិតផល> នៅកន្លែងនោះ ត្រឹមត្រូវទេ? <>

**ឆ៖** ដូចខ្ញុំជម្រាបអ៊ីចឹងផ្នែករើសផលិតផល។

**ស៖** លោកស្រីបានលើកឡើងអំពីផលិតផលមួយចំនួនមានកាហ្វេនេះ កាហ្វេហ្នឹងតើជាកាហ្វេរបៀបម៉េចដែរ? ប្រភេទម៉េចដែរ?

**ឆ៖** គឺកាហ្វេជាគ្រាប់។

**ស៖** ចុះ<ចំណែកឯ កប្បាស វិញ>?

**ឆ៖** ខ្ញុំអត់យល់។

**ស៖** អ៊ីចេះ ផ្នែកមួយទៀតនៃការងារដែលលោកស្រីនៅធ្វើនៅទីនោះផងដែរនោះ គឺការងារមួយចំណែកនោះ លោកស្រីជាអ្នកវិចខ្ចប់ ជាអ្នក<ច្រកកប្បាស> អ៊ីចឹងមែនទេ?

**ឆ៖** អត់ទេ អំបោះ តែខ្ញុំគ្រាន់តែមានតួនាទីជាអ្នកបកគ។ គហ្នឹងគេបក ហើយគេទៅគ្រីបច្រកនឹងបាល់ៗវាតែម្តង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** អ៊ីចឹងផ្នែកមួយនៃការ<ងាររបស់លោកស្រី តើលោកស្រីធ្វើការនៅរោងចក្រប្រមូលគ នៅតាខ្មៅដែរឬទេ>?

**ឆ៖** ត្រង់ហ្នឹងខ្ញុំ នាងខ្ញុំពុំបានដឹងដែរ តែគ្រាន់តែនាងខ្ញុំដឹងថា នាងខ្ញុំធ្លាប់គ្រឹបជាគៗដាក់បាវក្នុងហ្នឹងមានចំណុះជាង១០០គីឡូ ១០០។ ក្នុងហ្នឹងមានផលិតផលគហ្នឹងចំនួន១០០គីឡូ តែមានសំបកបាវថែមទៀត។ ១០២គីឡូ ឬក៏១០៣គីឡូ នាងខ្ញុំមិនបានចាំកន្លែងហ្នឹង។

[០៩:៤៨:០១]

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំបានបង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយមួយដែលលោកស្រីបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺនៅខែធ្នូ ឆ្នាំ២០០២ ERN ជាភាសាខ្មែរនោះគឺ 00054410, បារាំង 00332588, អង់គ្លេស 00640171។ នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសលោកស្រីនៅឆ្នាំ២០០២ គេបានសួរសំណួរមួយចំនួនទៅកាន់លោកស្រី។ "សួរថា៖ នៅឯរោងចក្រ<ផ្សេងទៀត តើ>លោកស្រីធ្វើអ្វីដែរ? លោកស្រីឆ្លើយថា៖ នៅទីនោះខ្ញុំធ្វើជាអ្នកប្រមូលគអស់មួយរយៈ ហើយមុននោះគឺថាគេបញ្ជូនខ្ញុំទៅឲ្យធ្វើការជាមួយមន្ទីរពាណិជ្ជកម្មក្នុងប្រទេស ដែលខ្ញុំហ្នឹងគឺថាជាអ្នកប្រមូលផលិតផលហ្នឹងដើម្បីគេនាំចេញទៅក្រៅ។ សួរ៖ ថាតើអង្គភាពពាណិជ្ជកម្មក្នុងប្រទេសមានទីតាំងនៅទីណាដែរ? ឆ្លើយ៖ គឺនៅ<ម៉ុំ>ទួលទំពូង។ សួរ៖ តើកន្លែងប្រមូលគនៅឯណាដែរ? កន្លែងប្រមូលគ គឺនៅជិតស្ពានមួយនៅតាខ្មៅ។ សួរ៖ ជាមួយនឹងគ គេយកគទៅធ្វើអ្វីដែរ? ឆ្លើយ៖ គឺថាគេដាក់ចងគ្រឹបវា<ជាបាល់មួយ> ទម្ងន់១០០គីឡូក្រាម។ តើនៅឆ្នាំណាដែរពេលនោះ? ឆ្លើយ៖ ថាខ្ញុំមិនចាំឆ្នាំណាទេ។ សួរ៖ តើលោកស្រីធ្វើការ<ដេរខោអាវ>នៅឯទួលទំពូងប៉ុន្មានឆ្នាំដែរ មុនពេលទៅ បញ្ជូនទៅឲ្យប្រមូលគហ្នឹង? <ឆ្លើយ៖ យូរដែរ។> ហើយសំណួរសួរថា៖ តើរយៈពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំដែរ? ឆ្លើយ៖ ថាខ្ញុំនៅទីនោះមួយរយៈ ហើយក្រោយមកគេក៏ឲ្យទៅធ្វើការនៅ<កន្លែង>ពាណិជ្ជកម្ម។ សួរ៖ តើលោកស្រីធ្វើការនៅកន្លែងប្រមូលគហ្នឹងប៉ុន្មានខែដែរ? ឆ្លើយ៖ គឺថាខ្ញុំធ្វើការនៅកន្លែងប្រមូលគហ្នឹងមិនដល់មួយឆ្នាំទេ។" តើចំណុចទាំងអស់នេះ វាជួយរំឭកដល់ការចងចាំរបស់លោកស្រីទេ នៅពេលដែលលោកស្រីទៅធ្វើការនៅកន្លែងប្រមូលគនៅឯតាខ្មៅនោះ?

[០៩:៥០:៣៨]

**ឆ៖** ខ្ញុំទៅធ្វើ នាងខ្ញុំទៅធ្វើប្រមូល ការប្រមូលគ គ្រឹបគនៅតាខ្មៅនោះ គឺមិនដល់មួយឆ្នាំទេ។

**ស៖** បន្ទាប់ពីនោះមកទៀត តើលោកស្រីចាប់ផ្តើមនៅឯទួលទំពូងនៅកន្លែង<>រើសផលិតផល

នោះមែនទេ?

**ឆ៖** ខ្ញុំនៅទួលទំពូងដំបូង ចាប់ផ្ដើមចូលដំបូង។ រួចបានគេឲ្យទៅកន្លែងគ្រឹបគហ្នឹង តែនៅក្នុងអង្គភាពតែមួយហ្នឹង។

**សៈ** សូមអរគុណលោកស្រី។ ហើយក្រោយមកគេបានបញ្ជូនលោកស្រីទៅវត្ត<គោក>ខ្សាច់ អ៊ីចឹងមែន ឈ្មោះអ៊ីចឹងមែនទេនៅក្នុងខេត្តកណ្ដាល? គោកខ្សាច់។

**ឆ៖** ចាស បន្ទាប់មកគេក៏បញ្ជូននាងខ្ញុំឲ្យមកនៅវត្តគោកខ្សាច់។

**សៈ** តើគេបញ្ជូនលោកស្រីទៅទីនោះ ទៅវត្តគោកខ្សាច់ហ្នឹងនៅក្នុងឆ្នាំណាដែរ? ហើយ<ហេតុអ្វីបានជាគេបញ្ជូនលោកស្រីទៅទីនោះ>?

**ឆ៖** ខ្ញុំ នាងខ្ញុំមិនបានចាំឆ្នាំដែរ ព្រោះកាលនុំងក្រោយពីគេចាប់ សោ ភឹម ហើយៗទេ។ មកហ្នឹងមកគឺគេឲ្យមកធ្វើស្រែ ច្រូតស្រូវ។ ហើយនិងចាប់ តាហុង តាអឺមកហើយហ្នឹងទេ បានគេបញ្ជូនមក។

**សៈ** តើ តាហុង ជាអ្នកណា?

**ឆ៖** តាហុង គឺជាអ្នកទទួលខុសត្រូវនៅក្រសួងពាណិជ្ជកម្ម។

[០៩:៥៣:៣៧]

**សៈ** តើ តាហុង នោះជាមេរបស់លោកស្រីមែនទេ?

**ឆ៖** ជាអនុរបស់ តាវិទ្ធ។ ប្រធានធំ តាវិទ្ធ, តាវិទ្ធ មកបាន តាហុង ហ្នឹង។

**សៈ** តើ តាវិទ្ធ មានតួនាទីអ្វីដែរ?

**ឆ៖** តាវិទ្ធ គាត់មានតួនាទីជាប្រធានពាណិជ្ជកម្មក្នុងប្រទេស និងក្រៅប្រទេស។

**សៈ** ចុះ តាហុង វិញ តាហុង មានតួនាទីអ្វីដែរ?

**ឆ៖** គាត់ជាអនុរបស់ តាវិទ្ធ។

**សៈ** ចុះហេតុអ្វីបានជា តាហុង ត្រូវបានគេចាប់ខ្លួន?

**ឆ៖** ត្រង់ហ្នឹងនាងខ្ញុំពុំបានដឹងដែរ ព្រោះ--។

**សៈ** តើ តាហុង ត្រូវបានគេឆ្លើយទម្លាក់កំហុសថា ជាជនក្បត់ដែរឬទេ?

**ឆ៖** ចាស គាត់ត្រូវគេចោទថា ជាជនក្បត់ហើយ ព្រោះគាត់ត្រូវគេចាប់ខ្លួននៅកន្លែងធ្វើការ។

**សៈ** តើលោកស្រីបានឃើញគេចាប់គាត់ដោយផ្ទាល់ភ្នែកដែរឬទេ?

**ឆ៖** ខ្ញុំពុំបានឃើញដោយផ្ទាល់ភ្នែកទេ តែបាត់គាត់។

**ស៖** តើនៅពេលដែលគេចាប់ តាហុង ពេលហ្នឹងលោកស្រីបានរៀបការហើយឬនៅ?

**ឆ៖** នៅពេលដែលគេចាប់ តាហុង នាងខ្ញុំបានរៀបការហើយ គឺនាងខ្ញុំរៀបនៅខែ១០ ឆ្នាំ ១៩៧៧។

**ស៖** ចុះប្តីលោកស្រីមានមុខងារធ្វើអ្វីដែរ?

[០៩:៥៧:២៩]

**ឆ៖** គាត់គ្មានមុខងារជាអ្វីទេ តែគាត់ជាអ្នកបើកឡាន បើកអីឲ្យ តាហុង ហ្នឹង។

**ស៖** តើមានអ្វីកើតឡើងចំពោះប្តីលោកស្រីដែរ?

**ឆ៖** នាងខ្ញុំអត់ដឹងដែរ ក្រោយពីគេចាប់គាត់ តាហុង ទៅ គេក៏ចាប់គាត់ទៅ។

**ស៖** តើធ្វើដូចម្តេចបានជាលោកស្រីដឹងថា ប្តីរបស់លោកស្រីនោះ ក៏ត្រូវបានគេចាប់ខ្លួនដែរ?

**ឆ៖** ព្រោះគាត់នៅក្រសួងពាណិជ្ជកម្មហ្នឹងដែរ។

**ស៖** តើលោកស្រីបានឃើញគេចាប់ប្តីលោកស្រីដោយផ្ទាល់ដែរ ឬក៏លោកស្រីឮពីអ្នកណាម្នាក់ប្រាប់លោកស្រីទេ?

**ឆ៖** នាងខ្ញុំពុំបានឮគេថាទេ តែគាត់ប្រាប់នាងខ្ញុំថា “ខ្ញុំគេឲ្យទៅហើយ”។

**ស៖** តើក្រោយមកលោកស្រីបានជួបប្តីលោកស្រីឡើងវិញទៀតទេ ចាប់តាំងពីពេលលោកស្រីធ្វើការនៅក្រសួងពាណិជ្ជកម្ម?

**ឆ៖** មិនដែលជួបទេ។

**ស៖** ចុះ តាហុង គាត់មានប្រពន្ធកូនដែរឬទេ? ហើយបើគាត់មានប្រពន្ធ មានកូន តើប្រពន្ធ និងកូនៗរបស់ តាហុង ហ្នឹង វាមានរឿងរ៉ាវអ្វីកើតឡើងទៅដល់អ្នកទាំងនោះដែរ?

**ឆ៖** តាហុង គាត់មានចៅ មានប្រពន្ធ ក៏ត្រូវគេចាប់ទៅដែរ គឺចាប់ទៅមុនគ្រួសារខ្ញុំទៀត។

[១០:០០:២៦]

**ស៖** ចុះមូលហេតុអ្វីបានជាគេបញ្ជូនលោកស្រីទៅវត្តគោកខ្សាច់?

**ឆ៖** នាងខ្ញុំមិនដឹងដែរ តែមិនមែនបញ្ជូនតែនាងខ្ញុំទេ គឺបញ្ជូនគ្នាច្រើនណាស់ ចំនួនពីរឡានក្រុងថ្ងៃនោះ។

**ស៖** នៅពេលដែលលោកស្រីទៅដល់វត្តគោកខ្សាច់ នៅទីនោះមានអ្នកដទៃទៀតស្នាក់នៅវត្ត

01377330



នោះដែរឬទេ?

**ឆ៖** មាន គឺមានច្រើនណាស់ នៅពេញតែវត្តហ្នឹងតែម្តង។

**ស៖** លោកស្រីបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍គឺ E3/10721 គឺចម្លើយលេខ១៧១។ គេបានសួរលោកស្រីថា៖ “តើលោកស្រីអាចពន្យល់បន្ថែមបានទេថា គោលបំណងនៃការបញ្ជូនទៅវត្តគោកខ្សាច់នេះ គឺដើម្បីគោលបំណងអ្វីដែរ? លោកស្រីបានឆ្លើយថា៖ គឺជាកន្លែងលត់ដំ ហើយអ្នកដទៃទៀតបាននិយាយថា គេយកមនុស្សទៅសម្លាប់ចោលនៅវត្តស្តែង។” នៅត្រង់ចម្លើយលេខ៩៣ -- បាទ ១៧៣ លោកស្រីបានឆ្លើយថា៖ “នៅវត្តគោកខ្សាច់ហ្នឹង គឺថាមានមនុស្សច្រើនណាស់ ពីព្រោះថា គេបានបញ្ជូនទៅទីនោះ ប្រហែលជា៣០ឡានឯនោះ ហើយគេដឹកតាមឡាន<ទ្រុង>ចិនហ្នឹងពីរឡាន<ទៅកន្លែងនោះដោយប្រើពេលយូរដែរ>។” <តើចំណុចនេះធ្វើឲ្យ>លោកស្រី<នឹកឃើញឡើងវិញពី>មូលហេតុអីបានជាគេបញ្ជូន<លោកស្រី និងអ្នកផ្សេងទៀត>ទៅវត្តគោកខ្សាច់នោះដែរឬទេ?

**ឆ៖** នាងខ្ញុំពុំដឹងទេ ប៉ុន្តែក្នុងមួយថ្ងៃៗ ឃើញតែបញ្ជូនម្តងពីរឡាន ម្តងពីរឡាន មានក្នុងមួយថ្ងៃពីរដើងអី។ តែដល់នាងខ្ញុំសួរទៅ អ្នកខ្លះសុទ្ធតែប្រពន្ធកងពល កងវរសេនាធំ។

**ស៖** តើអ្នកទាំងអស់នោះមានបានប្រាប់លោកស្រីថា មានអ្វីកើតឡើងទៅដល់ប្តីៗរបស់ពួកគាត់ដែរឬទេ?

[១០:០៣:៤០]

**ឆ៖** គឺសុទ្ធតែមិនដឹងដូចគ្នា តែក្នុងកន្លែងហ្នឹង ក៏មានយកៗមកក៏មានប្រុស មានស្រី។

**ស៖** តើលោកស្រីស្នាក់នៅវត្តគោកខ្សាច់ហ្នឹងអស់រយៈពេលប៉ុន្មាន<ដែរ? ប៉ុន្មាន>អាទិត្យ? <ឬ>ប៉ុន្មានខែដែរ?

**ឆ៖** នាងខ្ញុំស្នាក់នៅទីនោះ ទាល់តែច្រូតស្រូវហើយ ក៏ត្រូវពួកខ្មែរក្រហមបញ្ជូន ជញ្ជូនតាមឡានយកដាក់រទេះភ្លើងវត្ត – រទេះភ្លើងវ៉ាសំរោងអណ្តែត បញ្ជូនទៅកំពង់ឆ្នាំងវិញ។

**ស៖** នៅក្នុងចម្លើយរបស់លោកស្រី លោកស្រីថា គេបញ្ជូនលោកស្រីទៅព្រលានយន្តហោះកំពង់ឆ្នាំង ត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ពិតមែន។

**ស៖** សហការីរបស់ខ្ញុំនឹងសួរលោកស្រីបន្ថែមទៅលើចំណុចអម្បាញ់មិញនេះ ព្រលានយន្តហោះនេះ។ ឥឡូវខ្ញុំសូមសួរលោកស្រីអំពីវគ្គរៀនសូត្រជាមួយបក្សកុម្មុយនីស្តកម្ពុជា។ លោកស្រីបានឆ្លើយថា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<--> តើលោកស្រីបានក្លាយខ្លួនជាសមាជិកពេញសិទ្ធិនៃបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** ចាស បានក្លាយខ្លួនជាគណបក្សប្រជាជនកម្ពុជា -- នេះចេះច្រឡំ គណបក្ស ប៉ុល ពត។

**ប្រធានអង្គជំនុំ៖**

សំណួរសួរថា លោកស្រីបានចូលជាបក្ខជនៗនៅក្នុងជំនាន់ សម័យនោះដែរឬទេ?

**លោកស្រី ប៊ិត ប៊ឿន៖**

**ឆ៖** ចាស នាងខ្ញុំធ្លាប់បានចូល គឺចូលនៅឆ្នាំ១៩៧៧។

[១០:០៦:៤៤]

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** អ៊ីចឹងក្នុងឋានៈលោកស្រីជាបក្ខជន ថាតើលោកស្រីមានធ្លាប់បានចូលរួមវគ្គរៀនសូត្រជាមួយនឹងសមាជិកដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** ចាស នាងខ្ញុំធ្លាប់ចូលរួមរៀនសូត្រជាមួយគណបក្សកុម្មុយនីស្តកម្ពុជា គណបក្សកុម្មុយនីស្ត ប៉ុល ពត។ ភ័យចេះតែ ភ័យ វាងភ្លេចៗ។

**ស៖** តើលោកស្រីបានចូលរួមរៀនសូត្រ ដោយមានវត្តមានថ្នាក់ដឹកនាំបក្សកុម្មុយនីស្តដទៃទៀតឡើងបង្រៀននោះដែរឬទេ?

**ឆ៖** ចាស គឺមាន។ ប៉ុល ពត ជាប្រធាន, អនុប្រធាន នួន ជា, សមាជិក ខៀវ សំផន, អៀង សារី ក្រសួងការបរទេស និង អៀង ធីរិទ្ធ ផ្នែកសង្គមកិច្ច។

**ស៖** តើលោកស្រីបានចូលរួមរៀនសូត្របានប៉ុន្មានដងដែរ នៅ<ពេល>ដែលមានវត្តមានថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា<នៅទី>នោះ?

**ឆ៖** ធ្លាប់បានរៀនសូត្រពីរដង។ ហ្នឹងវគ្គធំៗ។

**ស៖** តើវគ្គរៀនសូត្រទាំងពីរវគ្គនេះ មានរយៈប៉ុន្មាន<ដែរ ពីរបីម៉ោង មួយ>ថ្ងៃដែរ ពីរបីថ្ងៃ <មួយ>សប្តាហ៍? អ៊ីចឹងលោកស្រីនៅចាំទេ វាមានរយៈពេលប៉ុន្មានថ្ងៃដែរ វគ្គរៀនសូត្រទាំងពីរវគ្គនេះ?

**ឆ៖** គឺក្នុងមួយវគ្គៗ គេរៀនសូត្រ៣ថ្ងៃ។

[១០:០៩:៣៨]

**ស៖** នៅក្នុងវគ្គរៀនសូត្រហ្នឹង អ្នកណាជាអ្នក<សំខាន់>ឡើងឧទ្ទេសនាម? តើថ្នាក់ដឹកនាំ<កំពូល>ណាខ្លះជាអ្នកឡើងនិយាយ ជាអ្នកឡើងឧទ្ទេសនាមក្នុងពេលរៀនសូត្រហ្នឹង?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ក្នុងពេលរៀនសូត្រហ្នឹងគឺ ប៉ុល ពត ជាអ្នកបើកកម្មវិធី ជាអ្នកឧទ្ទេសនាម។ បន្ទាប់មកគេក៏ឲ្យអនុ និងសមាជិកស្ដីងទៃទៀតចូលរួមមាន។

**ស៖** នៅពេលលោកស្រីបើពាក្យថា "អនុប្រធាន" តើលោកស្រីសំដៅអ្នកណា?

**ឆ៖** អនុប្រធានដូចខ្ញុំនិយាយអំមិញអ៊ីចឹងគឺមាន ប៉ុល ពត, នួន ជា, ខៀវ សំផន ហ្នឹងហៅអ៊ីចឹងមក។

**ស៖** នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកស្រី<ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា>គឺ E3/5647 អង់គ្លេស <00640152>, បារាំង -- ខ្មែរ 00054389 ទៅ90, បារាំង 00332572។ គេបានសួរលោកស្រីថា៖ "តើអ្នកណាជាអ្នកឡើងនិយាយក្នុងនិយាយក្នុងវគ្គរៀនសូត្រនេះ? តើជា ខៀវ សំផន ឬក៏ នួន ជា? លោកស្រីឆ្លើយថា៖ នួន ជា គឺជាអ្នកបង្រៀន។" នៅក្នុងវគ្គរៀនសូត្រទាំងនេះ តើ ខៀវ សំផន នេះមានឡើងឧទ្ទេសនាមដែរទេ?

**ឆ៖** ចាស គាត់ក៏ធ្លាប់ឧទ្ទេសនាមដែរ។ តែប្រធានគេមានយោបល់ទៅ គេឲ្យអនុប្រធានសមាជិកហ្នឹងជួយបន្ថែមបន្ថយយោបល់ខ្លះ ដែលមានការចន្លោះខ្វះខាត។

**ស៖** តើលោកស្រីចាំទេ នៅក្នុងវគ្គរៀនសូត្រទាំងនេះ មេដឹកនាំរូបណាដែលឡើងនិយាយច្រើនជាងគេ?

[១០:១២:៥១]

**ឆ៖** អ្នកដែលឡើងនិយាយច្រើនជាងគេគឺ ប៉ុល ពត។

**ស៖** លោកស្រីថាលោកស្រីធ្លាប់បានចូលរួមរៀនសូត្រហ្នឹងពីរវគ្គ <រយៈពេល>៣ថ្ងៃ <ក្នុងរយពេលពីរឆ្នាំនោះ>។ តើនៅក្នុងវគ្គរៀនសូត្រទាំងពីរវគ្គនេះ <រយៈពេល៣>ថ្ងៃហ្នឹង គេបង្រៀនលោកស្រីអំពីអ្វីខ្លះដែរ?

**ឆ៖** គេបង្រៀនអំពីនយោបាយសតិអារម្មណ៍ចាត់តាំង ដូចការដឹកនាំធ្វើការងារ។ ខ្ញុំមិនសូវចាំដែរ អាហ្នឹងបើនិយាយ គេរៀនមានក្នុងសៀវភៅ ១ទង់បដិវត្តនោះ គេបង្រៀនក្នុងសៀវភៅហ្នឹង។

**ស៖** តើថ្នាក់ដឹកនាំទាំងហ្នឹង មាននិយាយអំពីមនោគមន៍វិជ្ជា<បក្ស>ឬក៏និយាយអំពីមនោគមន៍វិជ្ជាណាមួយពាក់ព័ន្ធទៅនឹងស្ថានភាពខ្មាំង<របស់បក្ស>ដែរឬទេ?

**ឆ៖** គេនិយាយអំពីសកម្មភាពខ្មាំងហ្នឹង។

**ស៖** ចុះតើពួកគាត់មាននិយាយប្រាប់ថា ខ្មាំងទាំងនោះគឺជាអ្នកណាដែរឬទេ?

**ឆ៖** គាត់មិនបាននិយាយខ្មាំងទាំងនោះជាអ្នកណាទេ តែនិយាយខ្មាំង ជួនកាលខ្មាំងជាឪពុកម្តាយ ខ្មាំងជាបងប្អូនរបស់យើង តើយើងហ៊ានកម្ទេចទេ បើសិនជាបងប្អូនម៉ែឪយើងជាខ្មាំង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វីណ្ស៊ៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីណ្ស៊ៀម ស្មីត៖**

**ស៖** លោកស្រីសាក្សី មុនពេលយើងឈប់សម្រាកនោះ គឺលោកស្រីបានឆ្លើយថា នៅពេលដែលនិយាយពីសកម្មភាពខ្មាំង នៅក្នុងវគ្គរៀនសូត្រទាំងនោះ គឺថាអ្នកដែលឡើងឧទ្ទេសនាម មិនបានប្រាប់ថា អ្នកដែលជាខ្មាំងនោះជាអ្នកណាទេ ក៏ប៉ុន្តែ<គាត់បាននិយាយ>ថា៖ “<ពេលខ្លះ> ខ្មាំងហ្នឹងជាឪពុកម្តាយ ជា<សាច់ញាតិ>របស់យើង តើយើងហ៊ាន<កម្ទេច>ខ្មាំងទាំងនោះទេ បើ<ឪពុកម្តាយរបស់យើងជា>ខ្មាំងទាំងនោះ<>?” នៅពេលដែលអ្នកឡើងឧទ្ទេសនាមសួរថាតើយើងហ៊ានកម្ទេច

<ខ្លាំង>ទេ <>អ៊ីចឹង តើពាក្យ “កម្មេច” ពេលហ្នឹងគឺចង់មានន័យថាដូចម្ដេចដែរ?

**លោកស្រី ប៊ិត ហឿន៖**

**ឆ៖** ចាស នាងខ្ញុំមិនដឹងដែរ “កម្មេច” ហ្នឹង។

[១០:៣៤:៣៦]

**ស៖** ខ្ញុំសូមយកចម្លើយដែលលោកស្រីបានឆ្លើយជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្មានឆ្នាំកន្លងមកហើយគឺ E3/5647 ERN ជាភាសាអង់គ្លេស 00640152, ខ្មែរ <005438990>*(ស៊ីក)*, បារាំង 00332572 ដល់ 73។ អ្នកសម្ភាសពីមជ្ឈមណ្ឌលឯកសារកម្ពុជាបានសួរលោកស្រី៖ “ថាតើគេមាននិយាយអំពីការជាប់ពាក់ព័ន្ធជាមួយវៀតណាម ឬក៏<>អ្នកដែលមានបងប្អូន<ញាច់ញាតិ> មានតួនាទីបណ្ដាស័ក្តិខ្ពង់ខ្ពស់នៅក្នុងរបប លន់ នល់ ឬក៏ថាអ្នកដែលមានជាប់ពាក់ព័ន្ធជាមួយនឹងខ្សែបណ្ដាញ សេ.អ៊ី.អា ឬកា.ហ្សេ.បេ ដែរឬទេ? លោកស្រីឆ្លើយថា៖ ចាស ខ្ញុំបានឮគេនិយាយអំពីគិញ ហើយនិងភ្នាក់ងារ កា.ហ្សេ.បេ។ សួរថាតើអ្នកដែលឡើងនិយាយជាអ្នកណាដែរ? ជា ខៀវ សំផន ឬក៏ជា នួន ជា? លោកស្រីថា នួន ជា នេះគឺជាអ្នកខទ្មេសនាមហើយ។”

សំណួររបស់ខ្ញុំសួរថា តើវាជួយឲ្យលោកស្រីនឹកឃើញទេ នូវអ្វីដែលគេបានយកមកពិភាក្សានៅក្នុងវគ្គរៀនសូត្រទាំងនោះ ថាអ្នកដែលជាប់ពាក់ព័ន្ធជាមួយនឹងវៀតណាមនោះគឺជាខ្មាំងហើយ ហើយអ្នកដែលជាអតីតមន្ត្រីរដ្ឋការរបប លន់ នល់ ហ្នឹងក៏ជាខ្មាំង ហើយអ្នកដែលជាគិញនោះ ដូចជា សេ.អ៊ី.អា, កា.ហ្សេ.បេ ហ្នឹងគឺសុទ្ធតែជាខ្មាំងហើយ? តើអ៊ីចឹង តើវាជួយឲ្យលោកស្រីនឹកឃើញថា នៅក្នុងវគ្គរៀនសូត្រហ្នឹង គេមានលើកឡើងនិយាយពីចំណុចអស់ទាំងហ្នឹងដែរឬទេ<នៅពេលដែលលោកស្រីបានចូលរួមជាមួយពួកគេនោះ>?

**ឆ៖** ចាស នាងខ្ញុំធ្លាប់ឮ ប៉ុល ពត លើកឡើងនិយាយពីសកម្មភាពទាំងអស់ហ្នឹងដែរ។

**ស៖** នៅក្នុងចម្លើយរបស់លោកស្រី លោកស្រីថា នួន ជា គឺជាគ្រូបង្រៀនហើយ ជាអ្នកខទ្មេសនាមហើយ។ តើ នួន ជា មាននិយាយពីចំណុចទាំងអស់នេះដែរឬទេ?

[១០:៣៧:២០]

**ឆ៖** អត់ទេ គេអ្នកខទ្មេសនាមគឺ ប៉ុល ពត។

**ស៖** សូមអរគុណ។ នៅពេលលោកស្រីធ្វើការនៅក្រសួងពាណិជ្ជកម្ម តើលោកស្រីដែលបានចូលរួមក្នុងពិធីប្រារព្ធខួបជ័យជម្នះ<ដែលខ្មែរក្រហមឡើងកាន់អំណាចនៅខែ>មេសា <រៀងរាល់ឆ្នាំ>

ដូចជាខួប<ខែ>មេសា ៧៦ ឬក៏ខួប<ខែ>មេសា ៧៧ ឬក៏ ៧៨? តើលោកស្រីដែល ធ្លាប់ដែលចូលរួមនៅក្នុងមហាសន្និបាត ឬក៏នៅក្នុងពិធីធំៗនេះដែរឬទេ?

**ធ៖** នាងខ្ញុំពុំដែលបានចូលរួមផង។

**ស៖** ខ្ញុំសូមយកចម្លើយមួយចំនួនដែលគេបាននិយាយនៅក្នុងខួបជ័យជម្នះទាំងនេះ <ហើយនេះគឺជាខួបជ័យជម្នះមួយគឺ>នៅថ្ងៃទី<១៥> មេសា ៧៨។ គឺឯកសារ E3/562, អង់គ្លេស S00010563, ខ្មែរ 00249989 ទៅដល់90, បារាំង 00280379 ដល់80។ លោកស្រីសាក្សី ខ្ញុំសូមយកចម្លើយទាំងនេះ មកសួរលោកស្រី គឺអ្វីដែលលោក ខៀវ សំផន បានឡើងនិយាយសម្រាប់ខួបថ្ងៃ១៧ មេសា ឆ្នាំ១៩៧៨។ បាននេះមានកំណត់ត្រានៃសុន្ទរកថារបស់គាត់។ នេះ<ជា>អ្វីដែលលោក ខៀវ សំផន បាននិយាយ ពាក់ព័ន្ធទៅនឹងវិស័យការពារជាតិ គាត់បាននិយាយថា៖ "យើងត្រូវបោសសម្អាតឱ្យអស់ទាំងស្រុងនូវភ្នាក់ងារ ក៏ដូចជាពួកវាតទីនិយម ពួកយួនឈ្លានពាន ចេញពីអង្គភាពកងរបស់យើង ក៏ដូចជាឲ្យអស់ពីទឹកដីកម្ពុជា<ជារៀងរហូត>។" នៅត្រង់ចម្លើយលេខ៦ គាត់និយាយ៖ "យើងត្រូវតែបោសបំបាត់ភ្នាក់ងារ សេ.អ៊ី.អា ឲ្យបានអស់ទាំងស្រុងពីអង្គភាពរបស់យើង និងពីទឹកដីកម្ពុជារបស់យើង។" លេខ៩ គាត់បាននិយាយថា៖ "យើងត្រូវពង្រឹងទាំងស្មារតី សាមគ្គីទាំងស្មារតី ទាំងកម្លាំងកាយ កម្លាំងចិត្តម្នាក់ៗ <អង្គភាពនីមួយៗ> និងទូទាំងប្រទេសទាំងមូល និងពង្រឹងអំពីការឯកភាពជាតិ ហើយនិងការតស៊ូដើម្បីកម្ទេចខ្មាំងគ្រប់រូបភាពទាំងអស់។ ជាពិសេស ពួកវាតទីនិយម ខ្មាំងយួន ដើម្បីរក្សាជាតិរបស់យើង រក្សាពូជសាសន៍ ជាតិសាសន៍របស់យើងតទៅមុខទៀត។"

[១០:៤០:៥៤]

គាត់ក៏បាននិយាយផងដែរនៅក្នុងសុន្ទរកថាហ្នឹងគឺ S00010565, បារាំង 00280383, ខ្មែរ 00249992។ គាត់បាននិយាយថា ក្នុង<ផ្នែក>ដឹកនាំ<ពលកម្ម> ត្រង់ចំណុចលេខ៥៖ "<យើង>ត្រូវតែបោសសម្អាត និងកម្ទេចសមាសភាពខ្មាំងដែលមានបង្កប់នៅក្នុងជួររបស់យើង ក្នុងជួរកម្មាភិបាលគ្រប់ជាន់ថ្នាក់ផ្សេងៗគ្នា រួមទាំងក្នុងស្ថាប័នផ្សេងៗផង។"

ខ្ញុំ<បាន>អាន<សេចក្តីថ្លែងការណ៍មួយចំនួនពី>សុន្ទរកថារបស់ ខៀវ សំផន ហើយលោកស្រីក៏បាននិយាយផងដែរ នៅពេលលោកស្រីចូលរួមនៅក្នុងវគ្គរៀនសូត្រហ្នឹងគឺថា មានការនិយាយគ្នាអំពីខ្មាំង។ តើភាសាដែល ខៀវ សំផន បានប្រើប្រាស់នៅក្នុងវគ្គប្រារព្ធខួបជ័យជម្នះហ្នឹង តើគេមានយកមក<>និយាយនៅក្នុងវគ្គរៀនសូត្រទាំងនេះផងដែរឬទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ផ៖** អត់ផង។

**ស៖** នៅក្នុងអង្គប្រជុំនៅ<ក្នុងអង្គភាព>ពាណិជ្ជកម្មក្នុងប្រទេស តើគេមាននិយាយអំពីការរែកមុខរកខ្មាំងនៅក្នុងកងរបស់លោកស្រី ឬក៏ថានៅក្នុងក្រសួងពាណិជ្ជកម្មទាំងមូលនោះដែរឬទេ?

**ផ៖** អត់មាន។

**ស៖** ខ្ញុំសុំជួយរំឭកដល់ការចងចាំរបស់លោកស្រី។ ដំបូងខ្ញុំសុំសួរលោកស្រីជាមុនសិន នៅពេលដែលលោកស្រីបានចូលរួមនៅឯវគ្គរៀនសូត្រទាំងនោះ តើអ្នកដែលឡើងបង្រៀននេះ អំពីគោលនយោបាយរបស់ខ្មែរក្រហម តើអ្នកដែលឡើងបង្រៀនហ្នឹង មានស្នើសុំឲ្យលោកស្រីជួយរែកមុខរកខ្មាំងនៅក្នុងកងរបស់លោកស្រីនោះដែរឬទេ?

**ផ៖** គេនិយាយដែរហ្នឹង។

[១០:៤៣:៥៧]

**ស៖** តើគេលោកស្រីអាចពន្យល់ជូនតុលាការបានបន្តិចបាន បន្ថែមបានឬទេថា គេឲ្យលោកស្រីជួយរែករកមុខខ្មាំងនៅក្នុងអង្គភាព នៅក្នុងកងរបស់លោកស្រីហ្នឹងដោយរបៀបណាដែរ?

**ផ៖** គេលើកឡើងថា ឲ្យយើងពង្រឹងជំហរ ដឹកនាំ រែកមុខរកឃាត -- រកជនក្បត់ ដែលមានបង្កប់ស៊ីរូងផ្ទៃក្នុងបដិវត្តន៍របស់យើង។

**ស៖** តើអ្នកឡើងបង្រៀនរបស់ហ្នឹង ថាតើគេមានប្រាប់លោកស្រីត្រូវតែស្វែងរកដោយវិធីណាមួយ ត្រូវតែរកឲ្យឃើញដោយរបៀបណាដែរទេ?

**ផ៖** អត់ៗមានផង។

**ស៖** ទាក់ទងទៅនឹងការប្រមូលគ នៅឯកន្លែងការដ្ឋាន<តើ>លោកស្រី<ជាមេបញ្ជាការនៅទីនោះឬ> តើ<>លោកស្រី គឺជាប្រធានអង្គភាពដែលប្រមូលគនោះ ឬក៏យ៉ាងណា?

**ផ៖** នៅក្នុងហ្នឹង កន្លែងប្រមូលផលិតផលហ្នឹង គឺមានប្រធានគេមួយទៀតឈ្មោះ មិត្តថា។ ទាល់តែទៅកន្លែងគ្រីបគ ហ្នឹងបានខ្ញុំទទួលផ្ដាច់មុខម្នាក់ឯង។

**ស៖** តើកន្លែងគ្រីបគហ្នឹង គឺស្ថិតនៅឯម្ដុំទួលទំពូងនោះមែនទេ?

**ផ៖** ចាស មិនមែនស្ថិតនៅទួលទំពូងទេ គឺនៅក្រុងតាខ្មៅ ជិតស្ពានថ្ម។

**ស៖** <ហើយ>ក្នុងវគ្គរៀនសូត្រនេះ <>គេឲ្យលោកស្រីជួយរែករកមុខខ្មាំង នៅពេលលោកស្រីរៀនសូត្រចប់ ហើយត្រឡប់ទៅកន្លែងលោកស្រីធ្វើការវិញនៅឯតាខ្មៅហ្នឹង លោកស្រីមានបានជួយ

វែករកមុខខ្មាំងដែរឬទេ?

[១០:៤៧:១៤]

**ឆ៖** ខ្ញុំមិនបាននេះទេ មិនដឹងទៅចាប់ខ្មាំងណាម្នាក់ ៗគាត់តែប្រើងធ្វើការខ្លាចតែងាប់។

**ស៖** លោកស្រីឆ្លើយថា លោកស្រីគឺបក្ខជននៃបក្សកុម្មុយនីស្តកម្ពុជា តើគេមានដកហូតឋានៈជាបក្ខជននេះពីលោកស្រីទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោកស្រី ប៊ិត បឿន៖**

**ឆ៖** នៅពេលដែលខ្ញុំមកពីតាខ្មៅវិញ គឺគេដកសិទ្ធិខ្ញុំនៅពេលនោះ គេដកមកដាក់នៅ មកឲ្យឈរជើងនៅក្រសួងពាណិជ្ជកម្មក្នុងប្រទេស ឯទួលទំពូងវិញ វត្តទួលទំពូងវិញ។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** តើហេតុអ្វីបានជាគេដកហូតសិទ្ធិជាបក្ខជនរបស់លោកស្រីនេះ?

**ឆ៖** ដឹងអី ខ្ញុំអត់ដឹងដែរ។

**ស៖** តើអ្នកណាជាអ្នកដែលបានប្រាប់លោកស្រីថា លោកស្រីត្រូវបានគេដកហូតសិទ្ធិឈប់ឲ្យធ្វើជាបក្ខជនតទៅទៀតហើយនោះ?

**ឆ៖** អត់ផង។ អត់មានពីណាប្រាប់ទេ គ្រាន់តែគេដកយើងមកបញ្ឈរជើង ហើយគេដកយើងមកគោកខ្សាច់ហ្នឹងតែម្តង ឲ្យមករៀនសូត្រ។ គេប្រាប់ថា ឲ្យមករៀនសូត្រ តែយកមកដាក់គោកខ្សាច់ហ្នឹង។

[១០:៤៩:៣៥]

**ស៖** តើគេដកលោកស្រីចេញពីកន្លែងគ្រីបគនេះ ដោយសារថា នៅក្នុងវគ្គរៀនសូត្រហ្នឹង គេបានណែនាំបង្គាប់ឲ្យលោកស្រីជួយវែករកមុខខ្មាំង ប៉ុន្តែលោកស្រីមិនបានជួយវែករកមុខខ្មាំងទេ។ តើនេះវាជាមូលហេតុមួយដែលនាំឲ្យគេដកហូតសិទ្ធិជាបក្ខជនរបស់លោកស្រីហ្នឹង ឬក៏<លោកស្រីមិនដឹងទេ>?

**កញ្ញា អង់តា ហ្គីសសេ៖**

<លោកប្រធាន។>

01377338


**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកស្រី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់នឹងសំណួរនេះ គឺសំណួរនេះហ្នឹងត្រូវបានចោទច្រើនដងមកហើយដោយសហព្រះរាជអាជ្ញា ហើយសាក្សីរូបនេះ គាត់បានឆ្លើយជាច្រើនដងដែរថាគាត់មិនដឹងទេពីមូលហេតុដែលគេដកគាត់ចេញនោះទេ។ អ៊ីចឹងសំណួរហ្នឹង គេបានឆ្លើយហើយ ឥឡូវនេះគាត់កំពុងតែយកពាក្យ យកចម្លើយពាក្យពេចន៍មកដាក់ចូលនៅក្នុងមាត់សាក្សីនេះហើយ។ អ៊ីចឹងខ្ញុំមិនអាចទទួលយកបានទេ លោកប្រធាន។

[១០:៥០:៤០]

**លោក វីណ្ឡៀម ស្មីត៖**

គឺថាខ្ញុំមិនបានយកពាក្យនេះបញ្ចុកចូលក្នុងមាត់សាក្សីទេ។ សាក្សីបានឆ្លើយថា គាត់នេះត្រូវបានគេប្រាប់ឲ្យជួយរែករកខ្សាំងក្នុងវគ្គរៀនសូត្រ ហើយ<គាត់ទើបតែបាននិយាយមុននេះថា គាត់>អត់បានជួយរែករកមុខខ្សាំង<នៅការដ្ឋានរបស់គាត់>ទេ។ អ៊ីចឹងខ្ញុំបានតាំងសំណួរនេះ ជាសំណួរមួយប្រកបដោយហេតុផល សួរថាតើនេះជាមូលហេតុដែលនាំឲ្យគេដកលោកស្រី <ឬក៏មិនមែនដោយសារមូល-ហេតុនេះទេ។ ខ្ញុំគិតថា នេះជាសំណួរមានហេតុផលត្រឹមត្រូវ ដើម្បីសួរដោយផ្អែកទៅលើព័ត៌មានថ្មីដែលសាក្សីបានឆ្លើយ>។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំគ្រាន់តែចង់ជម្រាបជូនថា សហព្រះរាជអាជ្ញាហ្នឹងគាត់ទាញការសន្និដ្ឋានខ្លួនឯង ហើយសាក្សីរូបនេះ គាត់ឆ្លើយប្រាប់ច្បាស់ហើយ ថាគាត់មិនដឹងពីមូលហេតុនៃការដកគាត់ចេញនោះទេ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ហ្នឹងមានមូលហេតុសមស្របហើយ ព្រោះសាក្សីឆ្លើយដូច្នេះមែន អ៊ីចឹងបន្តទៅសំណួរថ្មីទៀតសហព្រះរាជអាជ្ញារងអន្តរជាតិ។

**សួរដោយលោក វីណ្ឡៀម ស្មីត៖**

**ស៖** បាទ សូមអរគុណលោកប្រធាន។ លោកស្រីសាក្សី លោកស្រីបានឆ្លើយថាលោកស្រីបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឃើញ ខៀវ សំផន នៅក្នុងវគ្គរៀនសូត្រទាំងពីរវគ្គហ្នឹង ដែលលោកស្រីបានចូលរួមរៀនសូត្រក្នុងអំឡុងពេល២ឆ្នាំនោះ។ តើលោកស្រី<ធ្លាប់>បានឃើញ ខៀវ សំផន ទៅកន្លែងលោកស្រីធ្វើការ <ដើម្បីប្រជុំ>នៅឯទួលទំពូង<នៅពេលលោកស្រីធ្វើការនៅទី>នោះដែរឬទេ?

[១០:៥២:៣៧]

**លោកស្រី ប៉ិត ហឿន៖**

**ឆ៖** ចាស គាត់ធ្លាប់ចូលទៅប្រជុំជាមួយពួកខ្ញុំដែលជាបក្ខជន ៗនៅទីនោះដែរ ព្រោះគាត់ត្រូវមានតួនាទីក្តាប់ពួក ក្តាប់ក្រសួងពាណិជ្ជកម្មក្នុងប្រទេស និងក្រៅប្រទេសហ្នឹង។ ក្នុងមួយខែគឺពួកយើងត្រូវទៅប្រជុំម្តងក្នុងមួយខែ រយៈពេលមួយខែៗ។

**ស៖** នៅក្នុង -- តើអង្គប្រជុំទាំងនោះ ប្រារព្ធធ្វើឡើងនៅឯទួលទំពូងឬ ហើយបើប្រារព្ធធ្វើនៅម្តុំទួលទំពូង គេធ្វើនៅក្នុងកន្លែងណាមួយ អគារណាមួយដែរ?

**ឆ៖** កន្លែងប្រជុំហ្នឹង ខ្ញុំមិនចាំដែរ តែនៅអាផ្លូវចុះពីស្ពានជ្រោយចង្វារមក មានខាងស្តាំដៃមានសាលាមួយ សាលារៀនមួយរាងជ្រៅ ហើយពួកខ្ញុំប្រជុំនៅខាងឆ្វេងដៃហ្នឹង តែមិនដឹងកន្លែងស្អី។

**ស៖** តើលោកស្រីបានចូលរួមប្រជុំដោយមានវត្តមានរបស់ ខៀវ សំផន ហ្នឹងបានប៉ុន្មានដងដែរ? នេះខ្ញុំនិយាយតែពីរឿងអង្គប្រជុំទេ អត់និយាយពីវគ្គរៀនសូត្រទាំងពីរដែលលោកស្រីលើកឡើងនោះទេ។ អ៊ីចឹងតើលោកស្រីបានចូលរួមប្រជុំផ្ទាល់ជាមួយ ខៀវ សំផន បានប៉ុន្មានដងដែរ?

**ឆ៖** ទេមិនដឹងជា២ខែ ឬក៏៣ខែទេ ខ្ញុំមិនចាំដែរ។

**ស៖** នៅក្នុងអង្គប្រជុំទាំងនោះ តើគេមាននិយាយអំពីអ្វីដែរ?

**ឆ៖** ពី និយាយអំពីការដឹកនាំធ្វើការងារ ការគោរពវិន័យ បញ្ហាសតិអារម្មណ៍អីហ្នឹង។

**ស៖** តើនៅក្នុងអង្គប្រជុំទាំងនេះ មាននិយាយអំពីគោលនយោបាយពាក់ព័ន្ធទៅនឹងខ្មាំងដែរឬទេ?

[១០:៥៥:៣៣]

**ឆ៖** មាន មាននិយាយពីរឿងខ្មាំងសតិអារម្មណ៍អី ខ្ជិលច្រអូស ខ្ជិលធ្វើការងារអីហ្នឹង។

**ស៖** ចុះខ្មាំងដែល ខៀវ សំផន បាននិយាយនៅថ្ងៃទី១៥ មេសា ១៩៧៨ ក្នុងនោះមាននិយាយអំពីភ្នាក់ងារខ្មាំង<សេ.អ៊ី.អា> ភ្នាក់ងារវៀតណាម ហើយនិងខ្មាំងដែលបង្កប់នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា តើ ខៀវ សំផន នេះមានបានយកចំណុចពាក់ព័ន្ធទៅនឹងខ្មាំងទាំងអស់នេះ មកនិយាយក្នុងអង្គ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រជុំទាំងនោះដែរឬទេ?

**ឆ៖** នាងខ្ញុំពុំដែលឮផង។

**ស៖** តើហេតុអ្វីបានជាលោកស្រីជឿជាក់ថា ខៀវ សំផន នេះគឺជាអ្នកដែលមានតួនាទីក្តាប់ក្រសួងពាណិជ្ជកម្មទាំងមូលតែម្តង ទាំងក្នុងទាំងក្រៅហ្នឹង? វាមានមូលហេតុអីដែលនាំឲ្យលោកស្រីជឿថាគាត់មានតួនាទីបែបនេះ?

**ឆ៖** អត់ដឹងមូលហេតុទេ តែគ្រាន់ថ្នាក់លើចាត់តាំងឲ្យគាត់ចុះទៅប្រជុំជាមួយពួកខ្ញុំដែលជាបក្ខជនទាំងអស់ហ្នឹង។

**ស៖** តើមានមេដឹកនាំណាផ្សេងទៀត នៅក្នុងក្រសួងពាណិជ្ជកម្មហ្នឹងក្រៅពី ខៀវ សំផន?

**ឆ៖** --ផន។ មានមិត្ត តាហុង, តាវិទ្ធ, មិត្តថា, ឈ្មោះម្នាក់ទៀតឈ្មោះ អឿន។

**ស៖** តើបក្ខជនប៉ុន្មាននាក់ដែលបានចូលរួមនៅក្នុងការប្រជុំហ្នឹង គឺប៉ុន្មាន<ដែរ អាចមាន១០>, ២០, <>១០០ <ឬក៏ច្រើនជាងហ្នឹង>?

**ឆ៖** អត់ដល់ទេ។ មានតែខ្ញុំ មិត្តថា, មិត្តអឿន ហើយ តាហុង, តាវិទ្ធ តែប៉ុណ្ណឹងនាក់ហ្នឹង។

[១០:៥៨:៣៧]

**ស៖** អ៊ីចឹងក្នុងហ្នឹងរួមទាំង លោក ខៀវ សំផន ទេ?

**ឆ៖** ចាស។

**ស៖** លោកស្រីប្រហែលជាអាច ប្រហែលជាឆ្លើយរួចមកហើយ ប៉ុន្តែខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ថាតើលោកស្រីបានចូលរួមការប្រជុំប្រភេទហ្នឹងប៉ុន្មានដងដែរ? លោកស្រីថា<ប្រហែល>ប្រជុំមួយខែម្តង អ៊ីចឹងខ្ញុំចង់ដឹងថា លោកចូលរួមការប្រជុំជាមួយលោក ខៀវ សំផន និងការប្រជុំផ្សេងៗទៀតហ្នឹងប្រហែលជាប៉ុន្មានដងដែរ បើគិតទៅ?

**ឆ៖** មិនដឹងជាប៉ុន្មានដង។

**ស៖** លោកស្រីអាចប៉ាន់ប្រមាណបានទេថា មួយ ឬក៏ពីរ ប្រាំឬក៏ប្រាំមួយ ១០, ១១ ឬក៏លើសហ្នឹង? លោកស្រីគ្រាន់តែអាចផ្តល់ជាតួលេខប្រហាក់ប្រហែលមកបានហើយ មិនបាច់ទាល់តែច្បាស់ពេកទេ?

**ឆ៖** បើនិយាយទាំងរៀនសូត្រទាំងអីផង ប្រហែលជាប្រាំមួយដងអីហ្នឹង។

**ស៖** សូមអរគុណ។ លោកស្រីបាននិយាយថា ក្រោយពី តាហុង ត្រូវបានគេចាប់ខ្លួនទៅ និង

ក្រោយពេល សោ ភឹម ត្រូវបានគេចាប់ខ្លួន ក្រោយមកគឺគេបញ្ជូនលោកស្រីទៅវត្តគោកខ្សាច់។ <តើ> គេបញ្ជូនលោកស្រីទៅទីនោះដោយសារតែលោកស្រីជាប់ពាក់ព័ន្ធនឹង តាហុង ហើយគេបញ្ជូនលោកស្រីទៅលត់ដំ ឬក៏គេគ្រាន់តែបញ្ជូនលោកស្រីឱ្យទៅបំពេញការងារជាធម្មតាអីទេ មិនមែនជាការលត់ដំអីទេ?

[១១:០០:៥៥]

**ឆ៖** គឺគេបញ្ជូនឱ្យទៅលត់ដំ។

**ស៖** តើមានអ្នកណាផ្សេងទៀត ដែលគេត្រូវបានបញ្ជូនទៅ<>គោកខ្សាច់ហ្នឹង<ដើម្បីលត់ដំ> ឬក៏បញ្ជូនទៅដោយមានមូលហេតុអីផ្សេងទៀតទេ ក្រៅពីលត់ដំហ្នឹង?

**ឆ៖** ទៅច្រើននាក់ណាស់ ដឹក ដល់ដឹកមកកំពង់ឆ្នាំងវិញមួយរទេះភ្លើងយ៉ាងវែង។

**ស៖** ក្រោយពេលគេចាប់ខ្លួន តាហុង នៅក្នុងអង្គភាពរបស់លោកស្រី គឺនៅ<ក្នុងអង្គភាព> ពាណិជ្ជកម្មក្នុងស្រុក មានអ្នកណាផ្សេងត្រូវបានគេចាប់ខ្លួន ហើយនាំយកទៅបាត់ទេ? លោកស្រីដឹងទេ?

**ឆ៖** មានគេចាប់ខ្លួនទៅ។ គេចាប់ទៅច្រើន រាប់រយនាក់ ប៉ុន្តែមិនដឹងគេយកទៅណាទេ ក៏ខ្ញុំមិនដឹងដែរ។

**ស៖** នៅក្នុងអង្គភាពពាណិជ្ជកម្មក្នុងប្រទេសលោកស្រីហ្នឹង មានអ្នកណាដែលមកពីភូមិភាគបូព៌ាទេ?

**ឆ៖** អ្នកភូមិភាគបូព៌ាច្រើន និរតីអី ឧត្តរអីតិចទេ។

**ស៖** លោកស្រី ដឹងថា ហេតុអីបានជាគេចាប់ខ្លួនអ្នកមកពីបូព៌ាទាំងហ្នឹងទេ?

**ឆ៖** នាងខ្ញុំពុំបានដឹងដែរ។

**ស៖** តើអ្នកដែលចាប់ខ្លួនហ្នឹង ភាគច្រើនគេចាប់ក្រោយពេលគេចាប់ តាហុង ឬក៏មុនពេលគេចាប់ តាហុង ហ្នឹងមានគេចាប់ខ្លួនអ្នកផ្សេងទៀតដែរហើយនៅក្នុងអង្គភាពពាណិជ្ជកម្មក្នុងប្រទេសហ្នឹង?

**ឆ៖** ក្រោយពីគេចាប់ តាហុង។

[១១:០៤:០៥]

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកស្រីសាក្សី។ ខ្ញុំអស់សំណួរហើយលោកប្រធាន ហើយខ្ញុំឱ្យសហការីរបស់ខ្ញុំគាត់មានសំណួរខ្លះទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញសហព្រះរាជអាជ្ញារងជាតិ!

**លោក សេង លាង៖**

អរគុណលោកប្រធាន។ ហើយចំពោះពេលវេលាយើងបានពិភាក្សាជាមួយនឹងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីហើយៗ។ ជាបឋម ខ្ញុំបាទសូមគោរពលោកប្រធាននិងអង្គសវនាការទាំងមូល។

**សួរដោយលោក សេង លាង៖**

**ស៖** សូមគោរពលោកស្រីសាក្សី។ ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិ។ ថ្ងៃនេះខ្ញុំមានសំណួរបន្តពីសហការីរបស់ខ្ញុំបន្តទៀត សួរទៅលោកស្រី។ ហើយពីព្រឹកមិញលោកស្រីបានមានប្រសាសន៍អំពី តាហុង ថាមានការចាប់ខ្លួន តាហុង ដែលមានចៅ មានប្រពន្ធ តាហុង។ លោកស្រីអាចបញ្ជាក់បានទេ ថាតើគេចាប់គាត់យកទៅណា?

**លោកស្រី ប៊ិត ហឿន៖**

**ឆ៖** ចាស ខ្ញុំពុំដឹងដែរ។

[១១:០៥:២២]

**ស៖** អរគុណលោកស្រី។ ប៉ុន្តែតាមកំណត់ហេតុស្ដាប់ចម្លើយរបស់លោកស្រី គឺឯកសារ E3/10726 ត្រង់ចម្លើយ១៨៣។ គេសួរលោកស្រីថា៖ "លោកស្រី មុនគេចាប់ទៅគោកខ្សាច់ គ្រួសារ តាហុង, ចៅតាហុង រួមទាំងប្ដីលោកស្រី ត្រូវគេចាប់ទៅ តើគេចាប់យកទៅដាក់គោកខ្សាច់ ឬកន្លែងណា? លោកស្រីឆ្លើយថា៖ មិនដឹងទៅណាទេ ខ្លះទៅជើងឯក ខ្លះទៅទួលស្លែង។ យើងមិនដឹងដែរណាជំនាន់ហ្នឹង។" តើលោកមានប្រតិកម្មយ៉ាងម៉េចដែរ ចំពោះចម្លើយនេះ?

**ឆ៖** ខ្ញុំមិនច្បាស់។ សុំបញ្ជាក់ម្ដងទៀត។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រីជាមួយនឹងអ្នកស៊ើបអង្កេតរបស់សាលាក្តី គឺនៅក្នុងឯកសារលេខ E3/10721 ត្រង់ចម្លើយ សំណួរចម្លើយលេខ១៨៣។ អ្នកស៊ើបអង្កេតគាត់សួរលោកស្រីថា៖ "លោកស្រី មុនគេចាប់ទៅគោកខ្សាច់ គ្រួសារ តាហុង, ចៅតាហុង រួមទាំងប្ដីលោកស្រី ត្រូវគេចាប់ទៅ តើគេចាប់ទៅដាក់គោកខ្សាច់ ឬកន្លែងណា? លោកស្រីបានឆ្លើយថា៖ មិនដឹងទៅណាទេ ខ្លះទៅជើងឯក ខ្លះទៅទួលស្លែង ហើយមិនដឹងដែរជំនាន់ហ្នឹង។" តើយ៉ាងម៉េចដែរ ចម្លើយនេះ លោកស្រី?

**ឆ៖** ខ្ញុំក៏មិនដឹងដែរ តែជំនាន់ហ្នឹង វាមានកន្លែងបឹងជើងឯក កន្លែងខ្លះថាជាជ្រោះពេជ្រនិលផង

ខ្លះថាអីផង។ ឮតែពាក្យចចាមអារ៉ាមគេថា។

[១១:០៧:៣០]

**ស៖** អរគុណលោកស្រី។ ចុះពាក់ព័ន្ធនឹងគុកទួលស្លែង តើលោកស្រីមានចាំបានទេ តើនៅពេលណាដែលលោកស្រីដឹងថា មានគុកទួលស្លែង? តើលោកស្រីដឹងហ្នឹងនៅមុនពេល ឬក្រោយពេលការដួលរលំរបស់របបខ្មែរក្រហម?

**ឆ៖** ខ្ញុំទើបនឹងដឹងឥឡូវដែរហ្នឹង។ មានការដឹកទៅដើរលេងអ៊ីចឹងទៅ ខ្ញុំទៅទួលស្លែងហ្នឹងទៅបានដឹងហ្នឹង។

**ស៖** ដើម្បីរំឭកការចងចាំរបស់លោកស្រី ខ្ញុំសូមអានឯកសារមួយគឺឯកសារលេខ E3/5647 ដែលមាន ERN ជាភាសាអង់គ្លេស 00640180 ដល់82, និង ERN ជាភាសាខ្មែរ 00054420 និងដល់21, ERN ជាភាសាបារាំង 00332595 ដល់96។ ខ្ញុំសូមដកស្រង់ គេសួរលោកស្រីថា៖ “មីង កាលសម័យហ្នឹង មីងស្គាល់គុកទួលស្លែងដែរទេ? មីងថា៖ ស្គាល់ដោយសារជិះក្បែរហ្នឹង។” ចំពោះចម្លើយនេះ មីងយល់យ៉ាងម៉េចដែរ មីងនៅរក្សាអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំ ហ្នឹងហើយ កន្លែងហ្នឹងខ្ញុំចាំ។ កាលហ្នឹងខ្ញុំនៅក្រសួងពាណិជ្ជកម្ម នៅវត្តស្អី ភ្លេចហើយ ទួលទំពូង នៅវត្តទួលទំពូង។ ខ្ញុំធ្លាប់ជិះកាត់ កាលមកពីប្រជុំមួយខែម្តងអីនោះ ខ្ញុំក៏ជិះកាត់តាមហ្នឹង។ តាមហ្នឹង ក៏ដឹងថាកន្លែងហ្នឹងជាគុកទួលស្លែង។ ហើយគុកទួលស្លែងហ្នឹង ក៏មានរបងជាប់វត្តទួលទំពូងហ្នឹងដែរ។

**ស៖** អរគុណលោកស្រី។ លោកស្រីបានមានប្រសាសន៍ថា លោកស្រីធ្លាប់ជិះកាត់តាមហ្នឹង បន្ទាប់ពីមកពីប្រជុំក្រសួង។ តើនៅពេលដែលលោកស្រីជិះកាត់តាមហ្នឹង តើលោកស្រីមានដែលឮសំឡេងស្រែកអីដែរឬទេ ចេញពីគុកទួលស្លែងហ្នឹង?

**ឆ៖** ខ្ញុំមិនដែលឮសំឡេងស្រែកទេ។ តែឮសួរក្មេងៗវាយាមយប់ៗវាថា “មីងអើយ ឮតែសំឡេងស្រែកយប់មិញហ្នឹង” ក្មេងៗវានិយាយអ៊ីចឹង។

[១១:១០:៥២]

**ស៖** ដើម្បីរំឭកការចងចាំរបស់លោកស្រី ខ្ញុំសូមអានឯកសារដដែលគឺឯកសារ E3/5647 ត្រង់ ERN ជាភាសាអង់គ្លេស 00640175 ដល់76, ERNជាភាសាខ្មែរ 00054415, ERN ជាភាសាបារាំង 00332592។ គេសួរលោកស្រីថា៖ “ហើយមីងជិះកាត់ហ្នឹង មីងបានឮទេ? មីងឆ្លើយថា៖ អត់

01377344



ទេ ឮតែពេលយប់អី ឮស្រែកអី"។ តើចម្លើយនេះ មីងនៅចាំបានទេ?

**ឆ៖** ខ្ញុំធ្លាប់និយាយដែរ តែខ្ញុំនិយាយថា ឮក្មេងៗវានិយាយ ព្រោះក្មេងៗវាយាមយប់។

**ស៖** តើលោកស្រីឮក្មេងៗនិយាយហ្នឹង ក្មេងៗមានធ្លាប់ប្រាប់លោកស្រីទេ ថាតើគេស្រែកដោយសារមូលហេតុអី?

**ឆ៖** អត់ដឹងដែរ ប៉ុន្តែខ្ញុំថា ប្រហែលជាគេធ្វើទារុណកម្មពេល ធ្វើទារុណកម្មហើយ មើល បានមនុស្សហ្នឹងស្រែក។

**ស៖** ឥឡូវសំណួរមួយទៀត ពាក់ព័ន្ធនឹងគុកទួលស្លែងដដែល។ តើលោកស្រីអាចបញ្ជាក់បានទេ នៅសម័យហ្នឹង និយាយពីបញ្ហាគុកទួលស្លែងហ្នឹង តើនៅក្រសួងពាណិជ្ជកម្មហ្នឹង មានមនុស្សច្រើនទេ ដែលគេដឹងថា មានគុកទួលស្លែងហ្នឹង?

**ឆ៖** ចាស មាន ព្រោះក្រសួងខ្ញុំនៅហ្នឹង មន្ទីរអ៊ីចឹង មានផ្លូវធំមួយ ផ្លូវធំបុកពីស្ពានទូតចិនទៅហ្នឹង ហើយនៅខាងឆ្វេងដៃហ្នឹង គឺមានគេបាំងរបងស័ង្កសីចាស់ៗខ្ពស់ៗ នៅខាងឆ្វេងដៃហ្នឹងតែម្ដង មើលទៅ មើលទៅ ក្រឡេកទៅឃើញតែម្ដង ជិះផ្លូវហ្នឹងទៅ។

[១១:១៣:៤៦]

**ស៖** អ៊ីចឹងលោកស្រីចង់មានប្រសាសន៍ថា ក្រៅពីលោកស្រី គឺមានមនុស្សច្រើនទៀតដែលនៅក្រសួងពាណិជ្ជកម្មហ្នឹង ដឹងអំពីគុកទួលស្លែងហ្នឹង អ៊ីចឹងមែនទេ?

**ឆ៖** ចាស។

**ស៖** ឥឡូវដោយសារបញ្ហាពេលវេលា ខ្ញុំឆ្លងចូលទៅប្រធានបទមួយទៀត ពាក់ព័ន្ធជាមួយនឹងព្រលានយន្តហោះនៅកំពង់ឆ្នាំងវិញ។ មីង ព្រឹកមិញបានមានប្រសាសន៍ថា គេបញ្ជូនមីងទៅវត្តគោកខ្សាច់។ អ៊ីចឹងក្រោយពីចេញពីវត្តគោកខ្សាច់ទៅ គេបញ្ជូនមីងទៅណាទៀត មីងអាចប្រាប់បានទេ?

មីងអំមិញខ្ញុំសួរមីងថា ក្រោយពីគេបញ្ជូនមីងចេញពីគោកខ្សាច់ តើគេបញ្ជូនមីងទៅណាទៀត មីងអាចឆ្លើយបានទេ?

**ឆ៖** ក្រោយពីមកនៅគោកខ្សាច់ គេបញ្ជូននាងខ្ញុំដឹកតាមឡានទៅរ៉ាសំរោងអណ្ដែត ទៅរ៉ារទេះភ្លើងសំរោងអណ្ដែត។ បន្ទាប់មកដឹកតាមរទេះភ្លើង មិនដឹងជាទៅចុះអីណាទេ ចុះតាមក្នុងព្រៃ ដឹងចុះកន្លែងណា ខ្ញុំអត់ចាំកន្លែង។ ដល់កន្លែងហ្នឹងគេឈប់ ហើយបានមានឡានមកទទួលទៀត។

**ស៖** អរគុណមីង។ ដោយសារពេលវេលា ខ្ញុំសូមវិលងទៅប្រធានបទមួយផ្សេងទៀត ពាក់ព័ន្ធ

នឹងការរៀបការរបស់មីង ហើយបើមានពេល ខ្ញុំនឹងត្រឡប់មកសួរពាក់ព័ន្ធទៅនឹងព្រលានយន្តហោះនេះវិញ។ អ៊ីចឹងពីព្រឹកមិញមីងបានមានប្រសាសន៍ហើយ ពាក់ព័ន្ធជាមួយនឹងការរៀបការរបស់មីងគឺមីងថា មីងរៀបការនៅខែ១០ ឆ្នាំ១៩៧៧ នៅវេលាម៉ោង០៩:៥៧នាទីព្រឹកមិញនេះ មីងមានប្រសាសន៍អ៊ីចឹង។ ប៉ុន្តែនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់មីង គឺឯកសារ E3/10721 ត្រង់ចម្លើយ១៩២ មីងថា រៀបការនៅឆ្នាំ៧៨។ តើចម្លើយពីរហ្នឹង មីងច្រឡំ ឬក៏យ៉ាងម៉េច មីងអាចជួយបញ្ជាក់បានទេ?

[១១:១៦:៤២]

**ឆ៖** ៧៧, ៧៨ ប្រហែលជា៧៨ហើយមិនដឹង ៧៨។

**ស៖** អ៊ីចឹងមិនមែនខែ១០ ៧៧ទេ គឺ៧៨ អ៊ីចឹងមីងអ្ន ឬម៉េច?

**ឆ៖** ខែ១០ ៧៧ មិនទេ អ្ហែ៧៧ទេ! ប្រហែលជា៧៧។

**ស៖** អ៊ីចឹង៧៧ មិនមែន៧៨ទេ?

**ឆ៖** ចាស។

**ស៖** បាទ អរគុណៗ មីង។ តើលោកស្រីអាចរៀបរាប់បានទេ អំពីការរៀបការរបស់លោកស្រីហ្នឹង វាយ៉ាងម៉េចដែរ? ការរៀបការរបស់លោកស្រីហ្នឹង វាប្រព្រឹត្តទៅយ៉ាងម៉េច? ហើយកាលហ្នឹងលោកស្រីធ្វើការនៅឯណាដែរ អាចរៀបរាប់បានទេ លោកស្រី?

**ឆ៖** ខ្ញុំធ្វើការនៅក្រសួងពាណិជ្ជកម្មហ្នឹង។

**ស៖** លោកស្រីអាចលម្អិតបានបន្តិចទេថា តើអ្នកណាគេជាអ្នកស្នើលោកស្រីរៀបការ? ហើយនៅពេលណាដែរ? ហើយប្តីលោកស្រីជានរណា? ហើយលោកស្រីរៀបការហ្នឹងមានប៉ុន្មានគូដែរ អាចជួយលម្អិតបន្តិចបាន លោកស្រី?

**ឆ៖** គ្រួសារខ្ញុំជាអ្នកស្នើ រៀបការហ្នឹងតែមួយគូទេ។

[១១:១៨:២១]

**ស៖** តើការរៀបការតែមួយគូ របស់លោកស្រីហ្នឹង វាជារឿងធម្មតានៅក្នុងរបបកម្ពុជាហ្នឹង -- របបកម្ពុជាប្រជាធិបតេយ្យហ្នឹង ការរៀបការតែមួយគូហ្នឹង ជារឿងធម្មតា ឬក៏ការរៀបការច្រើនគូក្នុងពេលតែមួយហ្នឹង គឺជារឿងធម្មតា លោកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** ធម្មតា តែក៏មានពេលខ្លះគេមានច្រើនគូដែរ។

**ស៖** អរគុណលោកស្រី។ តើនៅពេលដែលគេស្នើសុំលោកស្រីរៀបការនោះ តើលោកស្រីមាន

សិទ្ធិក្នុងការជ្រើសរើសដែរឬទេ ថាបដិសេធមិនព្រមរៀបការ ថាខ្លួនមិនចង់រៀបការ ឬក៏មិនពេញចិត្ត នឹងអ្នកស្នើសុំ តើលោកស្រីមានសិទ្ធិហ្នឹងដែរឬទេ?

**ឆ៖** យើងពេញចិត្តក៏យើងយកទៅ តែបើគេរៀបការភាគច្រើន គឺគេពេញចិត្ត។

**ស៖** ខ្ញុំចង់ឲ្យលោកស្រីជួយបញ្ជាក់ករណីលោកស្រីឲ្យបានច្បាស់បន្តិច ថាតើនៅពេលដែលប្តីលោកស្រីស្នើមកនេះ តើលោកស្រីមានសិទ្ធិក្នុងការជ្រើសរើសដែរទេថា ក្នុងការបដិសេធថា បើសិនជាអត់ពេញចិត្ត គឺលោកស្រីប្រាប់ថា អត់យកទេ មិនពេញចិត្តទេ តែបើពេញចិត្តលោកស្រីរៀបការ? តើលោកស្រីមានសិទ្ធិហ្នឹងដែរឬទេ?

**ឆ៖** នាងខ្ញុំមានសិទ្ធិ។

**ស៖** ដើម្បីរំឭកការចងចាំរបស់លោកស្រី ខ្ញុំសូមអានឯកសារ E3/5647 គឺត្រង់ ERN ជាភាសាអង់គ្លេស 00640184 ហើយ ERN ជាភាសាខ្មែរគឺ 00054424 រហូតដល់25, ហើយ ERN ជាភាសាបារាំងគឺ00332598 ដល់99។ ហើយខ្ញុំសូមមិនអានទាំងអស់ទេ សូមស្រង់យកខ្លះដើម្បីចំណេញពេល។ គេបានសួរលោកស្រីថា លោកស្រីបានឆ្លើយថា៖ "មិនពេញចិត្ត គ្មានសិទ្ធិប្រកែកទេ។ អ្នកសួរសួរទៀតថា៖ ហេតុអីបានជាគ្មានសិទ្ធិប្រកែក? លោកស្រីបានឆ្លើយថា៖ ទេ មិនដឹងទេ ប្រុសៗគេស្នើយើង ៗមិនពេញចិត្ត ក៏យើងត្រូវតែយក។" ហើយតមកខាងក្រោមទៀត គេសួរលោកស្រីថា៖ "តើយើងអត់មានសិទ្ធិប្រកែក ខ្ញុំអត់ពេញចិត្តទេ។ អ្នកស្រីឆ្លើយថា៖ ប្រកែកតទៅទៀត ខ្លាំងហើយ។" តើលោកស្រីនៅចាំចម្លើយនេះដែរឬទេ?

[១១:២១:៥១]

**ឆ៖** ចំពោះគ្នាជាប្រជាជន គឺគ្នាមិនសូវមានសិទ្ធិដែរ។ ឲ្យតែអង្គការចាប់រៀបគឺត្រូវតែរៀបការ។

**ស៖** អ៊ីចឹងមីងចង់និយាយថា ប្រជាជនអត់មានសិទ្ធិក្នុងការប្រកែកទេ អ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស។

**ស៖** ចុះមីងវិញ ជាកម្មាភិបាល មីងមានសិទ្ធិប្រកែកដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** ដឹងម៉េចដែរកន្លែងហ្នឹង។

**ស៖** ក្រោយការរៀបការហើយ តើអ្នកមីងមានបានផ្សំដំណេកជាមួយគ្រួសារអ្នកមីងដែរឬទេក្រោយការរៀបការហ្នឹង? ហើយមានការណែនាំថា អ្នកមីងត្រូវតែរួមដំណេកជាមួយប្តីអ្នកមីងដែរទេក្រោយរៀបការហ្នឹង?

**ឆ៖** ក្រោយពីរៀបការទៅ អាហ្នឹងគេទៅតាមគូៗផងគេទៅ។ គេមិនបាច់មានការណែនាំ គេដឹងតែមួយគូ មួយគូគ្នាគេ។

[១១:២៣:៤២]

**ស៖** ចុះក្រោយពីលោកស្រីរៀបការហើយនោះ តើលោកស្រីធ្លាប់មានផ្ទៃពោះដែរឬទេ? ហើយមានរឿងអ្វីកើតឡើង ប្រសិនបើលោកស្រីមានផ្ទៃពោះ?

**ឆ៖** ក្រោយពីរៀបការហើយ ក្រោយពីរៀបការហើយ នៅពេលដែលគេចាប់គ្រួសារនាងខ្ញុំទៅ នាងខ្ញុំបាត់រដូវ៥ថ្ងៃ។ ហើយបន្ទាប់មក នៅពេលដែលគេចាប់គាត់ទៅហ្នឹង ពួកគេក៏ មិត្តថា នោះក៏ប្រាប់ថា អង្គការឲ្យយកកូនចេញ។ មិត្តថា មកប្រាប់ខ្ញុំអ៊ីចឹង ហើយគេរកពេទ្យ រកអីឲ្យចាក់ថ្នាំ។ នៅពេលដែលចាក់ថ្នាំយូរដែរ ទម្រាំនេះ។ ដល់ពេលនេះទៅ ឃើញធ្លាក់មកប៉ុនមេជើង។

**ស៖** អរគុណអ្នកមីង។ ចុះ មិត្តថា ដែលប្រាប់មីងឲ្យយកកូនចេញហ្នឹង គាត់មានប្រាប់ពីមូលហេតុអ្វីទេ ថាមូលហេតុអីបានគាត់ឲ្យមីងយកកូនចេញ?

**ឆ៖** ខ្ញុំមិនដឹងដែរ គ្រាន់តែគេថាអង្គការឲ្យយកកូន ឲ្យយកកូនហ្នឹងចេញ។

**ស៖** ឥឡូវបែរមកការរៀបការវិញ ប្រសិនបើមនុស្សស្រីម្នាក់ដែលមិនមានការស្នើសុំទេពីខាងភាគីបុរស តើគាត់អាចត្រូវគេចាត់តាំងឲ្យរៀបការដែរឬទេ?

**ឆ៖** នៅក្រសួងខ្ញុំ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១១:២៥:០៨]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់សំណួរនេះ ហើយសូមឲ្យសហព្រះរាជអាជ្ញារងជាតិលើកអង្គហេតុជាក់លាក់ ដោយមានឯកសារយោងមកផង។ បាទ សូមអរគុណ។

**លោក សេង លាង៖**

អរគុណលោកមេធាវីការពារក្ដី។ ខ្ញុំ នេះខ្ញុំសួរសំណួរបើកទេ ពីព្រោះនៅក្នុងឯកសារគឺឯកសារ E3/10727 គឺនៅក្នុងសំណួរចម្លើយលេខ១៩៩ គេសួរលោកស្រីថា៖ "ចុះបើស្រីហ្នឹងអត់មានគេស្នើសុំ

រៀបការ? ចម្លើយគាត់ឆ្លើយថា៖ អត់ទេ ខ្លះទៅអង្គការជាអ្នកចាត់តាំងហ្នឹង។" ខ្ញុំអត់ចង់អានឯកសារដំបូងបានខ្ញុំសួរសំណួរបើក។ សូមអនុញ្ញាតសួរសំណួរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សំណួរនេះអាចឆ្លើយបាន។ លោកស្រីមេធាវីឆ្លើយសំណួរ អាចសួរបានណ៎ាលោក សាក្សីឆ្លើយតបនឹងសំណួរបើសិនជាចាំ។

**សួរដោយលោក សេង លាង៖**

**ស៖** ខ្ញុំសូមបញ្ជាក់លោកស្រីម្តងទៀត។ ខ្ញុំចង់និយាយថា ករណីដែលមនុស្សស្រីម្នាក់ត្រូវ មិនត្រូវបានមានការស្នើសុំពីខាងបុរសសុំរៀបការទេ តើក្នុងករណីហ្នឹង អង្គការមានសិទ្ធិចាត់តាំងឱ្យគាត់រៀបការដែរឬទេ?

**លោកស្រី ប៊ិត ហឿន៖**

**ឆ៖** នៅក្នុងក្រសួងខ្ញុំ ខ្ញុំមិនបានដឹងដែររឿងហ្នឹង អត់ច្បាស់។

[១១:២៧:៥១]

**ស៖** ចុះក្នុងករណីដែលមនុស្សស្រលាញ់គ្នា ឧទាហរណ៍ថាគេស្រលាញ់គ្នា ហើយតែគេមិនបានរៀបការជាមួយគ្នាទេ។ តើក្នុងករណីហ្នឹងអាចមានបញ្ហាអីដែរទេលោកស្រី?

**ឆ៖** ក្នុងករណីហ្នឹងគឺមានម្នាក់ដែរ ឈ្មោះ អឿន នោះគេដក អង្គការដកចេញ។

**ស៖** អង្គការដកចេញ តើគេដកគាត់យកទៅណាដែរលោកស្រី?

**ឆ៖** ខ្ញុំអត់ដឹងដែរ។

**ស៖** ពាក្យដែលលោកស្រីថា "ដកចេញ" ហ្នឹង តើវាមានន័យយ៉ាងម៉េចដែរ លោកស្រីអាចជួយពន្យល់បានទេពាក្យហ្នឹង?

**ឆ៖** មិនដឹងគេបញ្ជូនទៅណា ខ្ញុំអត់ដឹងដែរ តែគ្រាន់ដកពីកន្លែងធ្វើការហ្នឹងមក។

**ស៖** ចាប់តាំងពីពេលហ្នឹងមក តើលោកស្រីមានដែលឮពីដំណឹងគាត់ ឬក៏បានជួបគាត់ទេ តាំងពីពេលហ្នឹងរហូតដល់ការដួលរំលំរបស់ខ្មែរក្រហមរហូតដល់បច្ចុប្បន្ន តើលោកស្រីដែលជួបគាត់ដែរឬទេ ឬក៏ទទួលដំណឹងអីពីមនុស្សម្នាក់ហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់សួរពីដំណឹងមនុស្សធំហ្នឹង ពោះធំហ្នឹង ឬអីម៉េច?

**ស៖** មនុស្សៗម្នាក់ដែលលោកស្រីថាគេដកចេញហ្នឹង លោកស្រីជួយបញ្ជាក់មើល លោកស្រី

ដែលបាន ចាប់ពីគេដកមកហ្នឹង រហូតទៅដល់ការដួលរំលំរបស់ខ្មែរក្រហម ហើយរហូតដល់បច្ចុប្បន្ន តើលោកស្រីបានធ្លាប់ជួបគាត់ ឬបានទទួលដំណឹងអីពីគាត់ដែរឬទេ?

[១១:២៩:៤៥]

**ឆ៖** មិនដែលទទួលដំណឹងអីទេ។

**លោក សេង លាង៖**

លោកប្រធានពេលវេលាអស់ហើយ អាចខ្ញុំអាចសុំ៥នាទី ១០នាទីទៀតដើម្បីសួរទៅប្រធានបទមួយទៀតបានឬទេ? អរគុណលោកប្រធាន។

**សួរដោយលោក សេង លាង៖**

**ស៖** ឥឡូវបែរមកប្រធានបទពាក់ព័ន្ធជាមួយនឹងព្រលានយន្តហោះកំពង់ឆ្នាំងវិញ។ នៅពេលដែលលោកស្រីទៅដល់ព្រលានយន្តហោះកំពង់ឆ្នាំងនោះ តើលោកស្រីមានឃើញស្ថានភាពយ៉ាងម៉េចដែរនៅព្រលានយន្តហ្នឹង ថាមានមនុស្សច្រើនឬទេ? ហើយទំហំព្រលានយន្តហោះហ្នឹងវាធំប៉ុនណាដែរលោកស្រីអាចប្រាប់បានទេ?

**ឆ៖** នៅក្នុងព្រលានយន្តហោះហ្នឹងគឺមានមនុស្សច្រើន ព្រោះពេលដែលគេដឹកខ្ញុំចូលមកហ្នឹង គឺពេលល្ងាចទៅហើយ ម៉ោងប្រហែលជាប្រាំ គឺមើលទៅទីណាក៏សុទ្ធតែមនុស្សដែរ។ ហើយដីក្នុងរង្វង់ហ្នឹងខ្ញុំឮគេថា ១០គីឡូម៉ែត្របួនជ្រុងសម្រាប់ធ្វើព្រលានយន្តហោះហ្នឹង។

**ស៖** និយាយពីមនុស្សដែលលោកស្រីមើលឃើញហ្នឹង តើលោកស្រីមើលឃើញពីទីតាំងណា ពីលើឡានដែលលោកស្រីជិះទៅ ឬក៏ពេលដែលលោកស្រីចុះដល់ក្រោមហើយ បានលោកស្រីមើលឃើញ ឬក៏ពេលណាមួយដែលលោកស្រីទៅកាន់ទីតាំងខ្ពស់ណាមួយ ដែលបានលោកស្រីមើលឃើញថា មានមនុស្សច្រើនហ្នឹង?

[១១:៣១:២៣]

**ឆ៖** មើលទៅនៅលើឡាន ហើយចុះពីឡានហ្នឹង មើលទៅឃើញតែព្រាត សុទ្ធតែមនុស្ស ដូចយើងទៅអុំទូកអ៊ីចឹង។ ទីណាក៏សុទ្ធតែមនុស្ស ហើយមនុស្សនោះក្បាលជង្គង់នោះធំជាងក្បាលទៀត។ ស្គមៗ ឃើញតែក្បាលជង្គង់។

**ស៖** អរគុណលោកស្រី។ លោកស្រីបានមានប្រសាសន៍ថា ឃើញមនុស្សច្រើន ហើយទីតាំងហ្នឹងលោកស្រីបានបញ្ជាក់ថា ប្រហែលជា១០គីឡូម៉ែត្របួនជ្រុង។ អ៊ីចឹងតើមនុស្សច្រើនហ្នឹង ច្រើនរាប់

រយនាក់ រាប់ពាន់នាក់ ឬក៏ដល់រាប់ម៉ឺននាក់ ឬក៏ច្រើនជាងនេះ តើលោកស្រីអាចប្រាប់បានទេ ប្រហែល?

**ឆ៖** ប្រហែលរាប់ម៉ឺននាក់ មិនមែនរាប់ពាន់ទេ។

**ស៖** អរគុណលោកស្រី។ ចុះនិយាយអំពីមនុស្សដែលគេបញ្ជូនទៅជាមួយនឹងលោកស្រីហ្នឹង តើមនុស្សទាំងអស់ហ្នឹងគេបញ្ជូនទៅពីណាទៅដែរ ពីអង្គភាពណា ឬក៏ពីស្ថាប័នណាដែរ? ឧទាហរណ៍ថា ពីក្រសួងពាណិជ្ជកម្ម ឬក៏ពីទីកន្លែងផ្សេងទៀត តើអ្នកទាំងអស់ហ្នឹងត្រូវគេបញ្ជូនទៅជាមួយលោកស្រីហ្នឹង បញ្ជូនទៅពីណាដែរ? អាចប្រាប់បានទេ?

**ឆ៖** ចង់និយាយថា បញ្ជូនពីគោកខ្សាច់ទៅ?

**ស៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ឆ៖** ចាស បញ្ជូនពីគោកខ្សាច់ហ្នឹង បញ្ជូន គេបញ្ជូនមកគ្រប់កន្លែង ពេលនេះគេបញ្ជូនមកគ្រប់កន្លែងមកតែម្ដង ហើយបានគេបញ្ជូនទៅកំពង់ឆ្នាំងហ្នឹង ទាំងកងទ័ព ទាំងអីហ្នឹង មកតែទាំងអស់ ទាំងគ្នាហ្នឹង។

[១១:៣៣:០៦]

**ស៖** លោកស្រីថាមានកងទ័ព តើមានប្រជាជនស៊ីវិល ឬក៏ក្មេងៗទៅជាមួយដែរឬទេ?

**ឆ៖** ឃើញសម្បូរតែកងទ័ព ហើយពួកស្រីៗ កម្រមានកូនក្មេងណាស់កន្លែងហ្នឹង។

**ស៖** តើគេបញ្ជូនទៅជាមួយនឹងលោកស្រីហ្នឹង លោកស្រីដឹងទេថា មានមនុស្សប្រហែលជាប៉ុន្មាននាក់ដែរ ឬក៏ប៉ុន្មានឡានដែរ លោកស្រីអាចចាំបានទេ ទៅជាមួយលោកស្រីហ្នឹង?

**ឆ៖** ទៅៗហ្នឹង បើទៅពីគោកខ្សាច់ទៅ គេដាក់តិចៗទេ គេអត់ហ៊ានដាក់ច្រើនទេ វាក្រោម២០នាក់អីទេ ប្រហែលជាចំនួន៥០ឡានដែរ។ ហើយបើបារ៉ុងរទេះភ្លើងនោះ តបារ៉ុងគេវែងហ្មង។ ហើយដល់ទៅដល់ព្រៃហ្នឹង គេដាក់ឈរពេញៗហើយ។ មិនច្រើនដល់ដូចយើងដឹកពីគោកខ្សាច់នេះទៅទេ។

**ស៖** អរគុណលោកស្រី។ ចុះតើមនុស្សដែលគេបញ្ជូនទៅជាមួយលោកស្រីហ្នឹង គឺជាមនុស្សធម្មតាដែលមិនមានពាក់ព័ន្ធនឹងនិន្នាការនយោបាយ ឬក៏ជាអ្នកដែលគាំទ្រដ៏ស្មោះស្ម័គ្រនឹងកម្មវិធីនយោ-បាយរបស់ខ្មែរក្រហម ឬក៏ជាមនុស្សទាំងអស់ហ្នឹង សុទ្ធតែជាមនុស្សដែលគេសង្ស័យថាមិនស្មោះត្រង់នឹងរបបខ្មែរក្រហម?

**ឆ៖** ចាស គឺសុទ្ធតែមនុស្សដែលពាក់ព័ន្ធ មិនស្មោះត្រង់នឹងខ្មែរក្រហម។

**ស៖** តើលោកស្រីអាចពន្យល់បានទេថា ពាក្យថា “មិនពាក់ព័ន្ធ” ហ្នឹង លោកស្រីចង់សំដៅទៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លើមិនពាក់ព័ន្ធនឹងរឿងអីដែរ?

[១១:៣៥:១៦]

**ធ៖** ខ្ញុំមិនដឹងដែរ អារឿងមិនពាក់ព័ន្ធហ្នឹង។ តែខ្ញុំយល់ថា មនុស្សទាំងអស់ហ្នឹងគឺសុទ្ធតែពួកពាក់ព័ន្ធហើយ។

**ស៖** ខ្ញុំចង់ឲ្យលោកស្រីជួយពន្យល់ពាក្យ "អ្នកជាប់ពាក់ព័ន្ធ" ហ្នឹងមានន័យថាម៉េច? គាត់ជាប់ពាក់ព័ន្ធនឹងរឿងអី? សៃស្រឡាយ ឬក៏នយោបាយ ឬក៏អីដែរ អ្នកទាំងអស់នុ៎ង? អាចបញ្ជាក់បានទេ?

**ធ៖** ខ្ញុំចង់និយាយថា គេដូចថា ចាត់ទុកថាជាខ្មាំងអ៊ីចឹង។

**ស៖** អរគុណលោកស្រី។ តើលោកស្រីអាចបញ្ជាក់បានទេថា ការទៅ បញ្ជូនទៅព្រលានយន្តហោះកំពុងឆ្នាំងហ្នឹង គឺគេចាត់តាំងឲ្យទៅធ្វើការងារធម្មតា ឬក៏ចាត់តាំងឲ្យធ្វើការងារក្នុងរូបភាព ដូចជាការដាក់ទណ្ឌកម្ម ឬក៏ការអប់រំកែប្រែអី? លោកស្រីអាចប្រាប់បានទេ?

**ធ៖** បើប្រុសៗ គឺគេឲ្យយកទៅវ៉ៃថ្ម វ៉ៃអី ជញ្ជូនថ្ម ជញ្ជូនអី។ ស្រី បើពួកស្រីៗខ្ញុំវិញ គឺគេឲ្យទៅធ្វើស្រែប្រាំងនៅកំពង់ឆ្នាំងក្រោម។

**ស៖** អ៊ីចឹង បើលោកស្រីអាចបញ្ជាក់បានទេថា មូលហេតុអ្វីដែលគេបញ្ជូនលោកស្រីពីគោកខ្សាច់ហ្នឹង ទៅកំពង់ឆ្នាំងដែរទេ? លោកស្រីអាចប្រាប់ពីមូលហេតុដែរឬទេ?

**ធ៖** ខ្ញុំមិនដឹងដែរ។

**ស៖** ដើម្បីរំឭកការចងចាំរបស់លោកស្រី ខ្ញុំសុំអានឯកសារ ធ្វើការដកស្រង់ឯកសារ E3/5647 ត្រង់ ERN ជាភាសាអង់គ្លេស 00640174, ERN ជាភាសាខ្មែរ 00054413, ERN ជាភាសាបារាំង 00332590។ ខ្ញុំសូមដកស្រង់ គេសួរថា លោកស្រីថា៖ "ចេញពីកន្លែងហ្នឹងដែរ? លោកស្រីឆ្លើយថា៖ ដកចេញហើយ បញ្ជូនមកគោកខ្សាច់ហ្នឹង ហើយបញ្ជូនគោកខ្សាច់ អត់ដល់មួយខែផងបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំង គេយកទៅវ៉ៃចោលនៅហ្នឹង។" តើលោកស្រីចាំបានទេ នូវការឆ្លើយចម្លើយនេះ?

[១១:៣៧:៣១]

**ធ៖** ខ្ញុំអត់នេះ អត់ដឹងផងកន្លែងហ្នឹង។ តែខ្ញុំគ្រាន់តែដឹងថា បញ្ជូនទៅកំពង់ឆ្នាំងហ្នឹង យកទៅហ្នឹង យកទៅឲ្យធ្វើស្រែប្រាំង ទាល់បញ្ជូនពីហ្នឹងតទៅទៀត។

**ស៖** ដោយសារបញ្ហាពេលវេលា ខ្ញុំសួរសំណួរចុងក្រោយទៅលោកស្រីមួយ តើលោកស្រីអាចរៀបរាប់បានទេអំពីលក្ខខណ្ឌការងារនៅកំពង់ឆ្នាំងហ្នឹង? តើស្ថានភាពការងារហ្នឹង មុនហ្នឹងលោកស្រី

បានមានប្រសាសន៍ហើយថា មនុស្សប្រុស គេឲ្យទៅវ៉ៃថ្ម ហើយមនុស្សស្រីឲ្យទៅធ្វើស្រែ។ តើលោកស្រីអាចរៀបរាប់ទេពីការងាររបស់លោកស្រីហ្នឹង ថាតើវាពិបាកម៉េច វាស្រួលម៉េច? ហើយការហូបចុក ការស្នាក់នៅ ឬក៏អនាម័យអីយ៉ាងម៉េចដែរ?

**ឆ៖** ការរស់នៅទីហ្នឹង គឺគេឲ្យហូបបបររាវៗ។ ស្នាក់នៅ រោងគេទៅ មួយល្វែងអីចឹងទៅដេកតម្រៀបគ្នាទៅ។

**ស៖** អ៊ីចឹងសុំមួយសំណួរចុងក្រោយទៀត សួរថាតើនៅវាលយន្តហោះកំពង់ឆ្នាំងហ្នឹង មានតែទាហាន ឬក៏មានទាំងស៊ីវិលដែរ ទៅធ្វើការនៅកន្លែងហ្នឹង? មឹងអាចបញ្ជាក់បានទេ?

**ឆ៖** គេយកមកគ្រប់មជ្ឈដ្ឋានតែម្តង។

[១១:៤០:១០]

**លោក សេង លាង៖**

អរគុណលោកប្រធាន។ ដោយសារពេលវេលា ខ្ញុំសូមបញ្ចប់សំណួរត្រឹមនេះ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះ តទៅរហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយកន្លះរសៀល។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៤១ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី។ ដំបូងនេះ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ យើងខ្ញុំមិនមានសំណួរអ្វីទេ លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ តទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោកស្រី។ ជាដំបូង ខ្ញុំចង់សួរលោកពាក់ព័ន្ធនឹងសកម្មភាពរបស់លោកស្រីមុនខែមេសា ឆ្នាំ៧៥។ លោកស្រីបានឆ្លើយថា លោកស្រីនៅក្នុងអង្គភាពធ្វើថ្នាំបុរាណប្រឆាំងនឹងជំងឺគ្រុនចាញ់ <វិលមុខ> រាករូសជាដើម។ ដូច្នេះខ្ញុំចង់ដឹងថា ពេលនុ៎ងអ្នកណាជាប្រធានអង្គភាពលោកស្រី? ហើយនៅក្នុងអង្គភាពនោះ មានគេហៅថា គ្រូពេទ្យ គ្រូខ្មែរទេ?

[១៣:៣៣:២២]

**លោកស្រី ប៊ិត ហឿន៖**

**ឆ៖** ខ្ញុំសូមឆ្លើយ ប្រធានមន្ទីររបស់ខ្ញុំឈ្មោះ តារ៉េត។ ហ្នឹងគាត់ទៅរៀននៅវៀតណាម។ ហើយនៅក្នុងអង្គភាព ក្នុងហ្នឹងនៅក្នុងអង្គភាពភូមិភាគពិសេស៣០៥ គឺមាន តារន រ៉េត ជាប្រធានភូមិភាគពិសេសហ្នឹង។

**ស៖** ខ្ញុំមិនដឹងថាតើសំណួរខ្ញុំច្បាស់ ឬក៏មិនច្បាស់ អ៊ីចឹងខ្ញុំព្យាយាមសួរឡើងវិញ។ មុន<ថ្ងៃ១៧> ខែមេសា ឆ្នាំ៧៥ នៅពេលដែលលោកស្រីទៅប្រមូលថ្នាំបុរាណនោះ ខ្ញុំចង់ដឹងថា អ្នកណាជាប្រធានអង្គភាពលោកស្រី?

**ឆ៖** រ៉េត ជាប្រធានមន្ទីរហ្នឹង?

**ស៖** លោកស្រីសាក្សី សូមនិយាយឈ្មោះហ្នឹងម្ដងទៀត អម្បាញ់មិញអ្នកបកប្រែគាត់ស្ដាប់អត់ឮ?

**ឆ៖** ឈ្មោះ តារ៉េត។

**ស៖** <តារិទ្ធ> ហ្នឹងហើយដែលក្រោយមកជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មហ្នឹងមែនទេលោកស្រី?

**ឆ៖** មិនមែនទេ។

**ស៖** ហើយអ៊ីចឹងខ្ញុំចង់សួរលោកស្រីថា នៅក្នុងអង្គភាពលោកស្រីហ្នឹងមានគ្រូខ្មែរទេ អ្នកដែលមានសមត្ថភាពព្យាបាលតាមថ្នាំបុរាណនោះ?

**ឆ៖** ប្រធានមន្ទីរហ្នឹងគាត់ជាអ្នករៀនពេទ្យមកពីប្រទេសវៀតណាម។

[១៣:៣៦:២១]

**ស៖** ឥឡូវនេះខ្ញុំចង់ផ្ដោតទៅលើខែមេសា ឆ្នាំ៧៥ រកស្រីបានឆ្លើយថា ក្រោយជ័យជម្នះលោកស្រីទៅភ្នំពេញ។ អ៊ីចឹងពេលដែលទទួលបានជ័យជម្នះហើយហ្នឹង លោកស្រីទៅភ្នំពេញហ្នឹងគឺជាលើកដំបូងហើយមែនទេ ដែលលោកស្រីទៅភ្នំពេញហ្នឹង?

**ឆ៖** ចាស។

**ស៖** កន្លែងដែលលោកស្រីមកដល់ដំបូងគេហ្នឹង នៅភ្នំពេញហ្នឹងកន្លែងណាដែរ លោកស្រីអាចរៀបរាប់បានទេ?

**ឆ៖** នៅលើស្ដាតហ្នឹងតែម្ដង។

**ស៖** មុននេះសហព្រះរាជអាជ្ញានិយាយអំពីស្ដាតអូឡាំពិក ក៏ប៉ុន្តែខ្ញុំអត់បានឮពាក្យហ្នឹងចេញពីមាត់លោកស្រីទេ <តើ>លោកស្រី<ចាំឈ្មោះ>ស្ដាត<ហ្នឹងទេ? តើវាពិត>ជាស្ដាតអូឡាំពិកហ្នឹង ឬក៏ស្ដាតណាផ្សេង?

**ឆ៖** គឺស្ដាតអូឡាំពិកហ្នឹង។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីជីវិតរបស់លោកស្រីនៅភ្នំពេញ ក៏ប៉ុន្តែមុនចូលទៅដល់ចំណុចហ្នឹង ខ្ញុំចង់ដឹងថា <នៅពេលដែលលោកស្រី>ទៅដល់ភ្នំពេញហ្នឹង <នៅ>ថ្ងៃទី១៧ មេសា ឆ្នាំ៧៥ហ្នឹង លោកស្រីស្គាល់មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យណាខ្លះ ក៏ដូចជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា? លោកស្រីស្គាល់ទេ ហើយសូមរៀបរាប់ឈ្មោះ និងមុខតំណែងរបស់ពួកគាត់ផង?

[១៣:៣៨:១៦]

**ឆ៖** ខ្ញុំ មុនពេលជ័យៗជម្នះ ១៧ មេសា ខ្ញុំស្គាល់តែ អ៊ំខៀវ ហើយ អ៊ំធុក គាត់ខាងផ្នែកពេទ្យ ហើយអ៊ំអីទៀត ខាងដី។ អ៊ំខៀវ, អ៊ំធុក ខាងស្អីទេ គាត់ខាងផ្នែកដី វាស់ដីៗហ្នឹង ខ្ញុំមិនស្គាល់ដែរ ភ្លេច ឈ្មោះគាត់ហើយ។ មានតែប៉ុណ្ណឹង។

**ស៖** អ៊ីចឹងមុនខែមេសា ឆ្នាំ៧៥ លោកស្រីស្គាល់តែអ្នកទទួលខុសត្រូវមួយចំនួននៅក្នុងសកម្មភាពការងាររបស់លោកស្រី និងនៅកន្លែងដែលលោកស្រីនៅ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស។

**ស៖** នៅពេលដែលលោកស្រីឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិ លោកស្រីនិយាយអំពីវគ្គរៀនសូត្រ ហើយលោកស្រីក៏បានលើកឈ្មោះមនុស្សមួយចំនួន ដូចជា ប៉ុល ពត, អៀង សារី, ខៀវ សំផន, នួន ជា ជាដើម។ ដូច្នេះខ្ញុំចង់ដឹងថា លោកស្រីដឹងអ្វីខ្លះពីពួកគាត់ទាំងអស់ហ្នឹងនៅក្នុងពេលវគ្គរៀនសូត្រហ្នឹង? ចំណុចទី១ ខ្ញុំចង់ដឹងថា លោកស្រីដឹងអ្វីខ្លះពី ប៉ុល ពត នេះ? ពាក់ព័ន្ធនឹង ប៉ុល ពត នេះ លោកស្រីដឹងទេពេលដែលគាត់មកបង្រៀនហ្នឹង គាត់មានតួនាទី ឬក៏តំណែងជាអ្វីដែរ?

**ឆ៖** តំណែងរបស់ ប៉ុល ពត គឺគាត់ប្រកាសខ្លួនគាត់ ៗជាប្រធាន ហើយ នួន ជា ជាអនុ, ខៀវ សំផន ជាសមាជិក ហើយ អៀង ធីរិទ្ធ ក្រសួងការបរទេស ហើយប្រពន្ធគាត់ប្រធានអី -- អៀង សារី ក្រសួងការបរទេស, អៀង ធីរិទ្ធ គាត់ខាងផ្នែកសង្គមកិច្ច។

**ស៖** ប៉ុល ពត ជាអ្នករៀបរាប់ឈ្មោះអ្នកទាំងអស់ហ្នឹង ហើយប្រកាសពីមុខងាររបស់ពួកគាត់ ឬក៏យ៉ាងម៉េចនៅថ្ងៃ<ហ្នឹង> នៅពេលរៀនសូត្រហ្នឹង?

**ឆ៖** ចាស ប៉ុល ពត ជាអ្នកប្រកាស។

[១៣:៤១:៤២]

**ស៖** ខ្ញុំនឹងនិយាយអំពីលោក ខៀវ សំផន នៅពេលក្រោយ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំចង់និយាយអំពីចំណុចមួយ។ លោកស្រីបាននិយាយថា លោកស្រីបានធ្វើការនៅតាខ្មៅ គឺប្រមូលគ គ្រីបគ ហើយក្រោយមកទៀត គឺលោកស្រីទៅធ្វើការនៅវត្តទួលទំពូង។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** ពាក់ព័ន្ធនឹងការងារលោកស្រីនៅទួលទំពូង លោកស្រីធ្វើការតែនៅក្នុងវត្តហ្នឹងទេ ឬក៏

លោកស្រីចេញទៅក្រៅវត្តដែរ?

**ធ៖** ធ្វើនៅក្នុងវត្តហ្នឹង។

**ស៖** លោកស្រីបានឆ្លើយថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ លោកស្រីបានចូលរួមវគ្គរៀនសូត្រពីរដង ហើយលោកថាក្នុងនោះមានលោក ខៀវ សំផន ចូលរួមផងដែរ។ ហើយកាលពីព្រឹកមិញ ពេលដែលលោកស្រីឆ្លើយទៅនឹងសហព្រះរាជអាជ្ញា លោកស្រីគិតថា បើរាប់ការប្រជុំនិងវគ្គរៀនសូត្រ ដែលលោកស្រីបានឃើញលោក ខៀវ សំផន ហ្នឹង លោកស្រីគិតថាប្រហែលជាប្រាំមួយដង។ គឺមានន័យថា វគ្គរៀនសូត្រពីរនៅបុរីកីឡា ហើយនិងកិច្ចប្រជុំបួន ពាក់ព័ន្ធនឹងបញ្ហាមន្ទីរពាណិជ្ជកម្ម។ អ៊ីចឹងខ្ញុំចង់សួរលោកស្រីពាក់ព័ន្ធនឹងកិច្ចប្រជុំនៅមន្ទីរពាណិជ្ជកម្ម។ តាមរយៈ<ចម្លើយ>ពីមុនរបស់លោកស្រី ខ្ញុំយល់ថាលោកស្រីមិនអាចបញ្ជាក់ថា ការប្រជុំហ្នឹងនៅកន្លែងណាឲ្យបានពិតប្រាកដទេ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ធ៖** ចាស ព្រោះខ្ញុំមិនចាំកន្លែងដែរ បើទៅតែម្តង អាហ្នឹងខ្ញុំស្គាល់ ដល់នេះខ្ញុំមិនដែលចូលភ្នំពេញ ខ្ញុំម៉េចដឹង។

[១៣:៤៤:១៥]

**ស៖** ពេលដែលលោកស្រីនិយាយថា លោកស្រីមិនដែលចូលភ្នំពេញហ្នឹង លោកស្រីចង់មានន័យថា លោកស្រីមិនដែលចេញពីវត្តទួលទំពូងទេមែនទេ លោកស្រីនៅធ្វើការតែនៅខាងក្នុងបរិវេណវត្តទេ មិនដែលចេញមកខាងក្រៅទេ មានន័យថាអ៊ីចឹងមែនទេ?

**ធ៖** ដូចថាមិនដែលដើរស្គាល់ភ្នំពេញសព្វកន្លែង ម្ល៉ោះហើយវាមិនសូវដឹង។

**ស៖** អ៊ីចឹងលោកស្រីបានបញ្ជាក់ហើយថា មុនខែមេសា ឆ្នាំ៧៥ លោកស្រីមិនដែលមកភ្នំពេញទេ អ៊ីចឹងច្បាស់ហើយគឺលោកស្រីមិនសូវស្គាល់ភ្នំពេញទេ។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់អំពីកិច្ចប្រជុំទាំងបួន ដែលលោកស្រីទៅចូលរួមនៅខាងក្រៅវត្តហ្នឹង លោកស្រីចាំទេថា លោកស្រីទៅប្រជុំនុំង លោកស្រីដើរទៅ ឬក៏លោកស្រីជិះ<ឡាន>ទៅ?

**ធ៖** ពេលទៅប្រជុំហ្នឹង គឺអង្គការបានបើកម៉ូតូឲ្យមួយ។ ខ្ញុំជិះម៉ូតូទៅប្រជុំ។

**ស៖** លោកស្រីបើកដោយខ្លួនឯង ឬក៏មានអ្នកគេឌុបលោកស្រីទៅ?

**ធ៖** បើកដោយខ្លួនឯង។

**ស៖** ពេលលោកស្រីទៅប្រជុំហ្នឹង លោកស្រីទៅតែម្នាក់ឯងទេ ឬក៏<បានឃើញ>អ្នកផ្សេង

ទៀត<ទៅចូលរួមប្រជុំហ្នឹង> ដែលគេទៅពីវត្ត<ដែល>លោកស្រី<ធ្វើការ>ដែរ?

[១៣:៤៦:២៦]

**ឆះ** ពេលទៅប្រជុំ បើនៅវត្តគោកខ្សាច់គឺមាន មិត្តថា មិត្តអីគេទៅដែរ។ នៅគោកខ្សាច់អី នៅទួលទំពូង គឺមាន មិត្តថា អីគេទៅជាមួយ។ ដល់ទៅនៅកន្លែងគ្រីបគ តាខ្មៅនោះ គឺជិះទៅតែម្នាក់ឯង។

**សះ** ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ លោកស្រីនិយាយពីប្រជុំ<នៅ>ពេលលោកស្រីនៅវត្តគោកខ្សាច់។ <តើខ្ញុំយល់>លោកស្រី<ត្រឹមត្រូវទេ តើលោកស្រីមានន័យថាលោកស្រី>បានទៅប្រជុំជាមួយនឹងសមាជិកមន្ទីរពាណិជ្ជកម្ម? មុនហ្នឹង ពេលដែលលោកស្រីឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ខ្ញុំសុំដកស្រង់ចម្លើយរបស់លោកស្រី គឺលោកស្រីបានឆ្លើយថា <>លោកស្រី<បាន>ទៅប្រជុំ<មួយដែល>លោកស្រីបានឃើញលោក ខៀវ សំផន។ ហើយក្រៅពីការប្រជុំរៀនសូត្រហ្នឹងគឺមានការប្រជុំតូចតាច ដែលមាន តាហុង, តាអឿន <នេះជាអ្វីដែលខ្ញុំឮ>, មិត្តថា ជាដើម ហើយក៏មាន <តា>វិទ្ធមានអីផងដែរ។ អ៊ីចឹងខ្ញុំយល់ត្រឹមត្រូវទេថា ការប្រជុំទាំងអស់ហ្នឹងគឺជាប្រជុំលក្ខណៈតូចតាច ចង្អៀតដែលមានគ្នាតិចតួចទេ ដូចដែលខ្ញុំបានរៀបរាប់ឈ្មោះហ្នឹង។ ត្រឹមត្រូវទេ?

**ឆះ** រឿងប្រជុំ ទៅប្រជុំហ្នឹង មិនមែននៅគោកខ្សាច់ទេ គឺខ្ញុំនៅវត្ត វត្តអីខ្ញុំថាអំមិញហ្នឹង វត្តទួលទំពូង នៅវត្តទួលទំពូង និងនៅតាខ្មៅ។

**សះ** ខ្ញុំដឹងថា លោកស្រីទៅតាខ្មៅមុន រួចហើយ ក្រោយមកបានទៅវត្តទួលទំពូង។ ហើយក្រោយពីចេញពីវត្តទួលទំពូងហ្នឹង លោកស្រីត្រឡប់ទៅតាខ្មៅវិញ ឬក៏យ៉ាងម៉េច?

**ឆះ** ចាស ក្រោយពីទៅវត្តទួលទំពូង បានទៅតាខ្មៅវិញ។

**សះ** ពាក់ព័ន្ធនឹងលោក ខៀវ សំផន លោកស្រីបានឆ្លើយថា ក្នុងពេលអប់រំ ប៉ុល ពត និយាយថាលោក ខៀវ សំផន ជាសមាជិក។ លោកស្រីដឹងពីមុខតំណែងពិតប្រាកដរបស់លោក ខៀវ សំផន ទេនៅសម័យនោះ?

[១៣:៥០:០០]

**ឆះ** នៅសម័យហ្នឹង ខ្ញុំមិនដឹងដែរ។ តែគ្រាន់តែដឹងថា គាត់នៅក្រោម -- ខៀវ សំផន នៅក្រោមតាម តាឆ្នួន ជា។

**សះ** ពេលដែលលោកស្រី<និយាយ>ថា <លោកស្រីបានដឹងហ្នឹង តើ>លោកស្រីបានព័ត៌មានហ្នឹងមកពីណាដែរ?

**ឆ៖** ចុះប្រធាន -- មានប្រធាន អនុប្រធាន សមាជិក។

**ស៖** លោកស្រីនិយាយពីប្រធាន អនុប្រធាន សមាជិកហ្នឹង លោកស្រីដឹងពីរចនាសម្ព័ន្ធហ្នឹងយ៉ាងម៉េចខ្លះដែរ? ហើយដឹងនៅពេលណា?

**ឆ៖** គេនិយាយហ្នឹង ពេល ប៉ុល ពត លើកប្រាប់ហ្នឹង លើកប្រកាសក្នុងពេលរៀនសូត្រហ្នឹង គាត់ជាប្រធាន, អនុប្រធាន នួន ជា, បន្ទាប់មក ខៀវ សំផន, បន្ទាប់ពី ខៀវ សំផន មក អៀង សារី, អៀង សារី មក អៀង ធីរិទ្ធ។ វាមានតាមថ្នាក់។

**ស៖** លោកស្រីគិតដោយខ្លួនឯង សន្និដ្ឋានដោយខ្លួនឯង ឬក៏ ប៉ុល ពត គាត់ប្រកាសប្រាប់ថា អ្នកនេះធ្វើអី អ្នកនេះធ្វើអី ច្បាស់លាស់អីចឹងតែម្តង?

**ឆ៖** គាត់ប្រកាសដែរ តែខ្ញុំមិនចាំ គ្រាន់តែដឹងថា ប៉ុល ពត ប្រធាន, នួន ជា អនុ, ខៀវ សំផន សមាជិក, បន្ទាប់មក អៀង សារី, អៀង ធីរិទ្ធ ប៉ុណ្ណឹង។ បើ អៀង សារី, អៀង ធីរិទ្ធ ហ្នឹងខ្ញុំចាំច្បាស់ អៀង សារី គាត់ក្រសួងការបរទេស, អៀង ធីរិទ្ធ ខាងផ្នែកសង្គមកិច្ច។

**ស៖** លោកស្រី ស្គាល់គណៈអចិន្ត្រៃយ៍ទេ?

**ឆ៖** អត់ស្គាល់ផង។

[១៣:៥៣:១៦]

**ស៖** ខ្ញុំសួរសំណួររកប្រភពព័ត៌មានហ្នឹង ពីព្រោះថា សហចៅក្រមស៊ើបអង្កេតក៏បានស្ដាប់ចម្លើយលោកស្រី។ ហើយលោកស្រីក៏បានឆ្លើយថា លោកស្រីស្មានថា អ្នកណាជាអ្នកណានុ៎ង។ ដូច្នេះខ្ញុំសូមដកស្រង់នូវចម្លើយរបស់លោកស្រី គឺឯកសារ E3/10721 សំណួរចម្លើយ១២៦ ដល់១៣១។ មុននឹងខ្ញុំដកស្រង់ ខ្ញុំចង់សួរលោកស្រី ថាលោកស្រីស្គាល់ សុន សេន ទេ? ហើយលោកស្រីដឹងថា គាត់មានមុខតំណែងអ្វីទេ?

**ឆ៖** សុន សឺន ហ្នឹងបែប គណៈភូមិភាគពិសេសហ្នឹង ឮគេហៅ អ៊ំសឺន១ គណៈភូមិភាគពិសេស ឈ្មោះ អ៊ំខៀវ ហ្នឹងមិនដឹង។

**ស៖** ហើយលោកស្រី ស្គាល់ វន វ៉េត ទេ?

**ឆ៖** វន វ៉េត ក៏ស្គាល់ ហ្នឹង។

**ស៖** វន វ៉េត ហ្នឹង គាត់មានមុខតំណែងអ្វីដែរ?

**ឆ៖** ដឹងមុខតំណែងអីទេ តែគាត់ អ៊ំវន វ៉េត ហ្នឹងគាត់នៅភូមិភាគពិសេសហ្នឹងដែរ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៣:៥៥:២២]

**ស៖** នៅក្នុងឯកសារដែលលោកស្រីផ្តល់ចម្លើយជូនសហចៅក្រមស៊ើបអង្កេត លោកស្រីឆ្លើយខុសពីហ្នឹងបន្តិច គឺឯកសារដែលខ្ញុំបានប្រាប់មុននឹងបន្តិច គឺពីសំណួរចម្លើយ១២៦ ដល់១៣១។ ខ្ញុំសូមអានជូនលោកស្រីស្តាប់<ដើម្បីជួយរំឭកការចងចាំរបស់លោកស្រី ហើយខ្ញុំនឹងអាន>ជាភាសាអង់គ្លេស។ "សំណួរ១២៦៖ នៅក្នុងបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកស្រីបានលើកឡើងពីមនុស្សម្នាក់ ឈ្មោះ សុន សេន មែនទេ? លោកស្រីឆ្លើយ៖ ចាស សុន សេន ហៅ វន វ៉េត ហ្នឹងទេដឹង? សួរ៖ ហេតុអ្វីលោកស្រីគិតថា សុន សេន និង វន វ៉េត ជាមនុស្សតែមួយ? ឆ្លើយ៖ ខ្ញុំមិនដឹងទេ។ សួរ៖ សុន សេន តំណែងអី? ឆ្លើយ៖ ខ្ញុំអត់ដឹងទេ។ សួរ៖ ចុះ វន វ៉េត វិញ គាត់មានមុខតំណែងអ្វីដែរ? ឆ្លើយ៖ គាត់ប្រធានភូមិភាគពិសេស មន្ទីរ៣០៥។ ខ្ញុំឮគេហៅគាត់ថា សុន សេន។ សួរ៖ លោកស្រីធ្លាប់ឃើញគាត់ទេ? ឆ្លើយ៖ សួរខ្ញុំពី វន វ៉េត មែនទេ? សួរ៖ សុន សេន មិនមែន វន វ៉េត ទេ? ឆ្លើយ៖ វន វ៉េត ខ្ញុំមិនដែលឃើញទេ ហើយ សុន សេន ក៏មិនដែលឃើញដែរ ឮតែគេថា។ សង្ស័យតែពួកគាត់ហ្នឹង ជាមនុស្សតែមួយ ក៏មិនដឹង។" សូមបញ្ចប់ការដកស្រង់។ លោកស្រី ៗនឹកឃើញឡើងវិញនូវអ្វីដែលលោកស្រីបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតទេ <ហើយពិតទេថា>តាមពិតទៅ លោកស្រីមិនដឹងថាអ្នកណាជា សុន សេន អ្នកណាជា វន វ៉េត ទេ មែនទេ?

[១៣:៥៨:០១]

**ឆ៖** ចាស។

**ស៖** ចំពោះលោក ខៀវ សំផន វិញ បាននិយាយជាលើកដំបូងថា គាត់បានចូលរួមក្នុងកិច្ចប្រជុំជាមួយនឹងមេរបស់លោកស្រីគឺ តាហុង និងតាវិទ្ធ។ <លោកស្រីបានបញ្ជាក់បញ្ហានេះជាលើកដំបូង> នៅពេលដែលសហចៅក្រមស៊ើបអង្កេតសួរលោកស្រីនៅដើមឆ្នាំ២០១៦ហ្នឹង <ហើយ>ពេលព្រឹកមិញ ពេលលោកប្រធានសួរលោកស្រី លោកស្រីបានឆ្លើយថា លោកស្រីចាំថា មុននឹងមកឃុំហ្នឹងគឺមានមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងសម្ភាសលោកស្រី។ នៅក្នុងសំណុំរឿង យើងមានបទសម្ភាសន៍ពីររបស់លោកស្រីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានលេខ E3/5647។ ការសម្ភាសលើកទី១ហ្នឹងចុះថ្ងៃទី០៧ ធ្នូ ឆ្នាំ២០០២ ហើយនិងការសម្ភាសមួយទៀត គឺចុះថ្ងៃទី គឺចុះឆ្នាំ២០០៤ គឺថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៤។ ដូច្នេះលោកស្រីចាំពេលដែលលោកស្រីត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាគឺបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជានោះ សម្ភាសលោកស្រីពីរដងហ្នឹងទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ផ៖** ចាស។

[១៤:០០:០១]

**ស៖** នៅក្នុងបទសម្ភាសលើកទី១ គឺនៅឆ្នាំ២០០២ យើងដឹងថា អ្នកសួរសំណួរលោកស្រីហ្នឹង គាត់បាននិយាយពីលោក ខៀវ សំផន។ ខ្ញុំសូមយោងទៅសម្រង់ទី១ គឺនៅក្នុងឯកសារ E3/5647, ERN ជាភាសាបារាំង 00332570, ជាភាសាអង់គ្លេស 00640150, ជាភាសាខ្មែរ 00054387។ នៅក្នុងហ្នឹង លោកស្រីបាននិយាយអំពីវគ្គរៀនសូត្រនយោបាយនៅបុរីកីឡា។ ពេលនោះអ្នកសម្ភាសលោកស្រីហ្នឹង គេបាននិយាយ៖ "មឹង ពេលដែលមឹងទៅដល់នោះ មឹងបានចូលរួមវគ្គរៀនសូត្រនយោបាយ ហើយមឹងបាននិយាយថា មឹងបានចូលរួមវគ្គរៀនសូត្រនយោបាយជាមួយ នួន ជា <និងជាមួយអ្នកផ្សេងដូចនោះដែរ>។ អ៊ីចឹងខ្ញុំចង់ដឹងថាការរៀនសូត្រហ្នឹងនៅកន្លែងណា? ពេលនុ៎ងលោកស្រីឆ្លើយថា៖ បាទកន្លែងហ្នឹងគេហៅថា បុរីកីឡាអ៊ីចឹង។"

បន្ទាប់មកទៀត នៅក្នុងសម្រង់ទី២ គឺ ERN ជាភាសាបារាំង 00332572, ជាភាសាអង់គ្លេស 00640151។ ចំពោះលេខ ERN ជាភាសាខ្មែរ គឺខ្ញុំមិនទាន់មានទេ ចាំខ្ញុំផ្តល់នៅពេលក្រោយលោកប្រធាន។ ពេលនុ៎ងគេសួរលោកស្រី គឺបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា សួរលោកស្រីថា៖ "អ្នកណាដែលគេចាត់ទុកថា ជាមនុស្សប្រភេទជាខ្មាំងបដិវត្តន៍ ដែលគេនិយាយក្នុងពេលប្រជុំនុ៎ង ដែលមាន ខៀវ សំផន, នួន ជា អ្នកបង្រៀននោះ? គេមានបានពន្យល់ទេ ថាតើគេមានលក្ខណៈវិនិច្ឆ័យយ៉ាងម៉េចខ្លះដើម្បីកំណត់ថា អ្នកណាជាខ្មាំងរបស់អង្គការនោះ? ពេលនោះលោកស្រីឆ្លើយថា៖ ពេលខ្លះទៅគេនិយាយថា ខ្មាំងនៅក្នុងខ្លួនយើង គឺគេនិយាយអ៊ីចឹងឯង។ គឺថាកាលណាមានខ្មាំងក្នុងខ្លួនអ៊ីចឹងទៅ ធ្វើឲ្យយើងហ្នឹងខ្ជិល។"

ដូច្នេះខ្ញុំចង់សួរលោកស្រីថា <តើ>លោកស្រីចាំ<ទេ តាមរយៈការអានឯកសារនេះ គឺជាលើកទី១ នៅពេលដែលគេនិយាយពីឈ្មោះលោកខៀវ សំផន តើលោកស្រីចាំទេ ថាតើអ្នកដែល>សម្ភាសន៍<លោកស្រីនោះជា>អ្នកនិយាយអំពីឈ្មោះ ខៀវ សំផន ហ្នឹងគឺអ្នកសម្ភាសន៍ហ្នឹងគេប្រាប់ឈ្មោះលោកស្រីទេ លោកស្រីមាននឹកឃើញទេ?

**ផ៖** ចាស។

[១៤:០៣:៥០]

**ស៖** ក្នុងសម្រង់ទី៣ គឺសហព្រះរាជអាជ្ញាគាត់បានដកស្រង់ គឺនៅ ERN ដដែលហ្នឹង គេសួរថា

អ្នកណាអ្នកនិយាយ ខៀវ សំផន ឬក៏ នួន ជា? ពេលនុ៎ងលោកស្រីឆ្លើយថាគឺ នួន ជា។ ដូច្នេះលោកស្រីសាក្សី លោកស្រីចាំទេថា នៅក្នុងពេលលោកស្រីផ្តល់បទសម្ភាសន៍ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា <ថាតើមានអ្នកណាម្នាក់ និយាយទៅកាន់>លោកស្រី<>អំពីឈ្មោះ<ថ្នាក់ដឹកនាំ>នៅមន្ទីរពាណិជ្ជកម្មនៅសម័យនោះ<ដែរឬទេ>?

លោកស្រីសាក្សី ប្រហែលជាខ្ញុំត្រូវរំឭកការចងចាំរបស់លោកស្រី ដើម្បីឲ្យងាយស្រួលនៅពេលដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាសួរលោកស្រីគឺនៅឯកសារ E3/5647 លោកប្រធាន ERN ជាភាសាខ្មែរដែលខ្ញុំមិនបានប្រាប់អម្បាញ់មិញនេះគឺ 00054389។ នៅក្នុងសម្រង់នេះគឺគេនិយាយអំពីការដក តាហុង ហើយលោកលោកស្រីក៏បាននិយាយឈ្មោះអ្នកដែលជាទទួលខុសត្រូវមន្ទីរពាណិជ្ជកម្ម ERN ជាភាសាបារាំងគឺ 00332566, ERN ជាភាសាអង់គ្លេស 00640144 និងទៅទំព័របន្ទាប់ទៀត និង ERN ជាភាសាខ្មែរ 00054381។ ពេលនោះគេសួរលោកស្រីដូចតទៅ ខ្ញុំសូមដកស្រង់៖ "<តើ> នៅពេលដែលគេដក ហុង ហ្នឹង រិទ្ធ នៅទីនុ៎ងទេ? ពេលនោះលោកស្រីឆ្លើយថា៖ នៅពាណិជ្ជកម្មជាតិ និងក្រៅប្រទេសហ្នឹងគឺ<គាត់>ជាអ្នកដឹកនាំ។ សួរ៖ ខ្ញុំមិនសួរអ៊ីចឹងទេ ពេលដែលគេដក តាហុង ហើយ និងអ្នកបូព៌ាហ្នឹង តើ វ៉ាន់ រិទ្ធ ហ្នឹងគាត់ដដែលទេ គេអត់ដកគាត់ចេញទេមែនទេ? ពេលនោះលោកស្រីឆ្លើយថា៖ ចាស គាត់នៅហ្នឹងដដែល។ សួរ៖ តើមីងធ្លាប់ស្តាប់ឮឈ្មោះ កុយ ធួន ឬ កុយ ធីត ទេ? ពេលហ្នឹងលោកស្រីឆ្លើយថា៖ គឺ តាធួក និង តាធុច ខ្ញុំស្គាល់គាត់។" អ្នកសម្ភាសលោកស្រីនៅថ្ងៃនោះ គាត់បានសួរសំណួរពីឈ្មោះ កុយ ធួន លោកស្រីដឹងទេថា អ្នកណាជា កុយ ធួន? ហើយគាត់មានមុខតំណែងអ្វីដែរ?

[១៤:០៧:៤៨]

**ឆ៖** កុយ ធួន ខ្ញុំមិនដែលស្គាល់ផង។ ធួន, ធួក ហ្នឹងខ្ញុំមិនដែលស្គាល់។

**ស៖** នៅក្នុងបទសម្ភាសន៍ហ្នឹងលោកស្រីឆ្លើយថា លោកស្រីស្គាល់គាត់។ ខ្ញុំសូមបន្តអានទៀត ក្រៅពីលោកស្រីបាននិយាយពីឈ្មោះ ធុច ហើយនិង ធួក ហ្នឹង គេក៏សួរលោកស្រីបន្តទៅទៀតថា៖ "កាលហ្នឹងគាត់ជារដ្ឋមន្ត្រីក្រសួងអីដែរ? លោកស្រីឆ្លើយថា៖ កាលហ្នឹងគាត់នៅខាងពេទ្យ ជំនាន់អាពត ហ្នឹងគេហៅថា អ៊ឹម ធុក, អ៊ឹម ធុក។ អ្នកសម្ភាសក៏សួរលោកស្រីតទៅទៀត៖ ចុះមីងអ្នកដែលនៅក្រសួងពាណិជ្ជកម្មអ្នកហ្នឹង និងអ្នកដែលធំជាង វ៉ាន់ រិទ្ធ ហ្នឹងអ្នកណាគេទៅ? លោកស្រីឆ្លើយថា៖ មានតែតាហ្នឹងទេ។" សូមបញ្ចប់ការដកស្រង់។ ពេលដែលខ្ញុំអានទៅ លោកស្រីនឹកឃើញឡើងវិញទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

អញ្ជើញលោកព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

នេះប្រហែលជាដោយសារតែបញ្ហាបកប្រែហើយមើលទៅ ប៉ុន្តែជាភាសាអង់គ្លេសគឺ<>សរសេរថា៖ “<អ្នកសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា សួរថា> ក្រសួងពាណិជ្ជកម្ម <តើអ្នកណាដែល>នៅពីខាងលើ វ៉ាន់ រិទ្ធ? <ហើយសាក្សីនិយាយថា គឺមានតែគាត់>ហ្នឹងហើយ។” ហើយជាភាសាអង់គ្លេសអត់មាន តាធុច ឬក៏ កុយ ធួន ឬក៏មានឈ្មោះអ្នកណាម្នាក់សរសេរនៅក្នុងឯកសារជាភាសាអង់គ្លេសនេះទេ។

[១៤:១០:00]

**កញ្ញា អង់តា ហ្គីសសេ៖**

ជាភាសាបារាំងដែលខ្ញុំអានហ្នឹង យើងយល់ច្បាស់ថាគឺមានតែតាហ្នឹងទេ វាអាចថា តាហ្នឹងជាសមមិត្ត ឬក៏ជាបងអីចឹង។ អីចឹងអត់មានចម្លើយអីបញ្ច្រាសគ្នាទេ ហើយ តាធុច, តាធួក <ដែលខ្ញុំនិយាយនោះគឺមាន>នៅចម្លើយ<ទៅនឹងសំណួរ>មុនឯណោះ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ដូច្នេះខ្ញុំចង់សួរលោកស្រីសាក្សីថា លោកស្រីនឹកឃើញអំពីអ្វីដែលលោកស្រីបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាទេ? គឺលោកស្រីពេលហ្នឹងឆ្លើយថា មានតែ វ៉ាន់ រិទ្ធ ហ្នឹង ហើយអត់មានអ្នកណានៅពីលើ វ៉ាន់ រិទ្ធ ហ្នឹងទេ លោកស្រីចាំចម្លើយហ្នឹងទេ?

**ឆ៖** ចាំ។

**ស៖** នៅឆ្នាំ២០០២ លោកស្រីបានឆ្លើយបែបនេះនៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយនៅឆ្នាំ២០០៤ ក៏លោកស្រីមិនបានលើកឡើងអំពី<តួនាទីគ្រប់គ្រងខ្ពស់ណាមួយជានេះនៅក្នុងក្រសួង>ពាណិជ្ជកម្ម<ទេ>។ ហើយលោកស្រីលើកឡើងអំពីមុខងារទទួលខុសត្រូវរបស់លោក ខៀវ សំផន នៅក្រសួងពាណិជ្ជកម្មហ្នឹង ជាលើកដំបូងគឺនៅពេលដែលគេ -- គឺនៅ១២ឆ្នាំ ឬក៏១៤ឆ្នាំក្រោយមកទៀត <ប្រសិនបើយើងគិតតាំងពីឆ្នាំ២០០៤មក> នៅពេលដែលអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតសួរលោកស្រីនោះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:១១:៤៥]

ខ្ញុំនឹងរំឭកឡើងវិញនូវអ្វីដែលលោកស្រីបានឆ្លើយជូន នៅក្នុងពេលលោកស្រីផ្ដល់ចម្លើយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/10721។ គឺសំណួរចម្លើយ២៤២ ដែលខ្ញុំនឹងអាចជាភាសាអង់គ្លេស៖ “នៅក្រសួងពាណិជ្ជកម្ម អ្នកដែលទទួលខុសត្រូវទាំងពាណិជ្ជកម្មក្នុង និងក្រៅប្រទេសគឺ ខៀវ សំផន។ គាត់បានប្រជុំជាមួយពួកហ្នឹង កម្មាភិបាលអស់ហ្នឹង មួយខែគេប្រជុំម្ដង។” បញ្ចប់ការដកស្រង់។

ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ឲ្យបានច្បាស់ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត លោកស្រីបាននិយាយថា មានការប្រជុំមួយខែម្ដង។ ហើយមុននេះនៅពេលដែលលោកស្រីឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា លោកស្រីថាលោកស្រីអត់ចាំថា ការប្រជុំហ្នឹងគឺ ២ខែម្ដង ឬក៏ ៣ខែម្ដងទេ។ លោកស្រីបានឆ្លើយថា លោកស្រីបានចូលរួមប្រជុំហ្នឹងប្រហែលជាប្អូនដងជាមួយលោក ខៀវ សំផន ដែលពាក់ព័ន្ធនឹងបញ្ហាពាណិជ្ជកម្ម។ ដូច្នេះខ្ញុំចង់សួរលោកស្រីរកប្រភពព័ត៌មានដែលលោកស្រីទទួលបាន។ តើលោកស្រីបានព័ត៌មានហ្នឹងមកពីណា? ឥឡូវខ្ញុំសួរអ៊ីចេះវិញ ក្នុងពេលប្រជុំដែលមានការផ្លាស់ប្ដូរយោបល់គ្នារវាង តាវិទ្ធ និង តាហុង លោកស្រីដឹងអំពីខ្លឹមសារនៃកិច្ចប្រជុំទាំងហ្នឹងទេ?

**ឆ៖** ខ្ញុំដឹង គឺមានគោលនយោបាយគេធំៗបី គឺនយោបាយសតិអារម្មណ៍ ចាត់តាំង។

**ស៖** ខ្ញុំនឹងសួរលោកស្រីតាមរបៀបផ្សេងវិញ។ ពេលដែលលោកស្រីធ្វើការនៅវត្តទួលទំពូង លោកស្រីមានតួនាទីអ្វីដែរ លោកស្រីទទួលខុសត្រូវខាងផ្នែកអីដែរ?

**ឆ៖** ទទួលខុសត្រូវខាងផ្នែករើសផលិតផល។

[១៤:១៥:០០]

**ស៖** មុននេះលោកស្រីនិយាយថា ការងារហ្នឹងនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងពាណិជ្ជកម្មក្នុងប្រទេស។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ចាស។

**ស៖** អ៊ីចឹងមានន័យថា ខាងផ្នែកពាណិជ្ជកម្មក្រៅប្រទេស ឬពាណិជ្ជកម្មអន្តរជាតិហ្នឹង លោកស្រីអត់មានតួនាទីអ្វីទេ មែនទេ?

**ឆ៖** ចាស។

**ស៖** ត្រឹមត្រូវទេដែលថា លោកស្រីបានចូលរួមក្នុងការប្រជុំហ្នឹង គឺពាក់ព័ន្ធតែនឹងការងាររបស់

លោកស្រី គឺពាក់ព័ន្ធតែនឹងពាណិជ្ជកម្មក្នុងប្រទេសទេ។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ផ៖** ចាស ត្រឹមត្រូវ។

**ស៖** លោកស្រីបានឆ្លើយថា លោកស្រី<មិន>ចាំថា តើការប្រជុំដែលលោកស្រីបានចូលរួមហ្នឹង ប្រព្រឹត្តទៅនៅកន្លែងណាទេ ក៏ប៉ុន្តែលោកស្រីថាវាមិនមែននៅវត្តទួលទំពូងទេ។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ផ៖** ចាស។

**ស៖** អ្នកណាជាអ្នកមកប្រាប់លោកស្រីថា លោកស្រីត្រូវទៅចូលរួមប្រជុំនៅថ្ងៃណា ថ្ងៃណាអ៊ីចឹង? អ្នកណាជាអ្នកកោះហៅលោកស្រីឱ្យទៅចូលរួមប្រជុំនៅមន្ទីរពាណិជ្ជកម្មក្នុងប្រទេសហ្នឹង?

[១៤:១៦:៥៨]

**ផ៖** អ្នកប្រាប់គឺ មិត្តថា។ តែយើងដឹងតែមួយខែ ត្រូវប្រជុំម្តងអ៊ីចឹងតែម្តង។

**ស៖** ក៏ប៉ុន្តែមុននេះ លោកស្រីបានឆ្លើយថា មិនដឹងថាតើការប្រជុំហ្នឹងមួយខែម្តង ពីរខែម្តង ឬក៏បីខែម្តងទេ។ ហើយពេលដែលលោកស្រីឆ្លើយទៅនឹងសហព្រះរាជអាជ្ញា លោកស្រីថា បើតាមលោកស្រីចាំ ក្រៅពីវគ្គរៀនសូត្រពីរដងនៅបុរីកីឡាហ្នឹង លោកស្រីចាំថា លោកស្រីបានចូលរួមតែការប្រជុំបួនដងប៉ុណ្ណឹង ដោយមានវត្តមានលោក ខៀវ សំផន នុ៎ង។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ផ៖** មិនត្រឹមត្រូវទេ។

**ស៖** មិនត្រឹមត្រូវ លោកស្រីបញ្ជាក់បន្តិចទៅមើល មិនត្រឹមត្រូវត្រង់កន្លែងណា?

**ផ៖** ព្រោះខ្ញុំធ្លាប់ជួបគាត់នៅកន្លែងរៀនសូត្រធំៗមួយឆ្នាំម្តង មួយឆ្នាំម្តងនោះពីរលើក។ ហើយប្រជុំនៅ បក្ខជននៅមន្ទីរពាណិជ្ជកម្មនេះបួនដង។

**ស៖** អ៊ីចឹងគឺត្រូវហើយ ខ្ញុំនិយាយអំមិញហ្នឹងអ៊ីចឹងហើយ គឺដូចលោកស្រីនិយាយអ៊ីចឹង។ ឥឡូវខ្ញុំសួរបន្តទៅមុខទៀត ខ្ញុំនឹងបន្តដកស្រង់នូវចម្លើយរបស់លោកស្រី ដែលលោកស្រីឆ្លើយជូនការិយាល័យសហចៅក្រមស៊ើបអង្កេត គឺសំណួរចម្លើយ២៤៣ ដែលលោកស្រីបាននិយាយអំពីការប្រជុំ<ទាំងបួន> ដែលលោកស្រីបានចូលរួម។ ពេលនុ៎ងគេសួរលោកស្រី ខ្ញុំសុំដកស្រង់ជាភាសាអង់គ្លេស៖ “អ្នកណាជាអ្នករៀបចំកិច្ចប្រជុំនោះ? ឆ្លើយ៖ កាលនោះ ខៀវ សំផន ហ្នឹងប្រធានបើកកម្មវិធី។ អត់ទេ! អត់ទេ ខ្ញុំចង់និយាយថា តាវិទ្ធ ជាអ្នករៀបចំកម្មវិធី ព្រោះគាត់ជាប្រធានពាណិជ្ជកម្មក្រៅប្រទេស។” បញ្ចប់ការដកស្រង់។ “សួរ៖ ប្រជុំហ្នឹងប្រជុំនៅកន្លែងណា? ឆ្លើយ៖ កន្លែងហ្នឹងគេហៅក្រសួងពាណិជ្ជកម្មក្រៅ

ប្រទេស។ សួរ៖ នៅក្នុងកិច្ចប្រជុំអស់ហ្នឹង គាត់និយាយអ្វីខ្លះ? ឆ្លើយ៖ កិច្ចប្រជុំហ្នឹង គេនិយាយតែនយោបាយ សតិអារម្មណ៍ និងចាត់តាំង<ការងារ>។” បញ្ចប់ការដកស្រង់។

[១៤:២០:១៣]

ដូច្នេះនៅក្នុងចម្លើយដែលលោកស្រីបានឆ្លើយជូនការិយាល័យសហចៅក្រមស៊ើបអង្កេត គឺយើងមានអារម្មណ៍ថា លោកស្រីបានលើកឡើងអំពីកិច្ចប្រជុំនៅមន្ទីរពាណិជ្ជកម្មក្រៅប្រទេស។ លោកស្រីក៏បានលើកឡើងអំពីខ្លឹមសារនៃការប្រជុំ ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មក្រៅប្រទេស។ លោកស្រីអាចបញ្ជាក់ចំណុចនេះបានទេ? លោកស្រីមានបានចូលរួមប្រជុំ ពាក់ព័ន្ធនឹងបញ្ហាពាណិជ្ជកម្មក្រៅប្រទេសទេ ឬក៏ពេលនុ៎ង លោកស្រីឆ្លើយហ្នឹង លោកស្រីគ្រាន់តែស្មានៗទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយសាក្សី!

សូមអញ្ជើញលោកព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីណ្ស្មៀម ស្មីត៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ពីព្រោះសាក្សីហាក់បីដូចមិនបាននិយាយថា កិច្ចប្រជុំនៅពាណិជ្ជកម្មក្រៅប្រទេសទេ។ ឯសំណួរសួរថា តើគេនិយាយអ្វីខ្លះនៅក្នុងអង្គប្រជុំនេះ? គាត់ឆ្លើយថា នៅក្នុងអង្គប្រជុំ គេនិយាយតែនយោបាយ សតិអារម្មណ៍ ហើយនិងចាត់តាំង<ការងារ> តែប៉ុណ្ណោះ។ សាក្សីរូបនេះ មិនបាននិយាយថា កិច្ចការរបស់គាត់ហ្នឹងគឺជាប់ទាក់ទងទៅនឹងផលិតផលដែលត្រូវបញ្ជូនទៅក្រៅប្រទេសនោះទេ <គឺមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់។ ប៉ុន្តែគាត់មិនបាននិយាយថា កិច្ចប្រជុំនោះនិយាយអំពីពាណិជ្ជកម្មបរទេស ទេ>។

[១៤:២១:៤១]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំនឹងសួរតាមរបៀបផ្សេងវិញ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកស្រីសាក្សី មុននេះបន្តិចលោកស្រីបានឆ្លើយថា លោកស្រីមិនចាំថា កិច្ចប្រជុំទាំងអស់ហ្នឹងប្រព្រឹត្តទៅនៅកន្លែងណាទេ គឺកិច្ចប្រជុំទាំងបួនលើកដែលលោកស្រីបានចូលរួម ហើយដែលលោក ខៀវ សំផន មានវត្តមាននោះ។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកស្រី ទី១ តើការប្រជុំហ្នឹងប្រព្រឹត្តទៅ

នៅក្រសួងពាណិជ្ជកម្មក្រៅប្រទេសមែនទេ?

**លោកស្រី ប៊ិត ហឿន៖**

**ឆ៖** ចាស គឺនៅម្ដុំ កន្លែងហ្នឹងម្ដុំស្ពាតចាស់ដែរហ្នឹង នៅផ្សារចាស់ សុំទោស នៅម្ដុំផ្សារចាស់ ចុះពីជ្រោយស្ពានហ្នឹងមកបន្ដិចមក។

**ស៖** កិច្ចប្រជុំទាំងបួនលើក ដែលលោកស្រីនៅចាំហ្នឹង គឺប្រព្រឹត្តទៅនៅកន្លែងហ្នឹងតែមួយទេ មែនទេ?

**ឆ៖** ចាស។

**ស៖** លោកស្រីថា តាវិទ្ធ ជាអ្នករៀបចំរបៀបវារៈនៃការប្រជុំ ហើយនិងជាអ្នកដឹកនាំកិច្ចប្រជុំ។ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

[១៤:២៣:៣១]

**ឆ៖** ចាស។

**ស៖** មុននេះលោកស្រីបាននិយាយថា លោកស្រីមិនដឹងថា លោក ខៀវ សំផន មានមុខតំណែងអ្វីទេ ក៏ប៉ុន្តែលោកស្រីដឹងទេថា នៅពេលដែលលោក ខៀវ សំផន គាត់ចូលរួមប្រជុំហ្នឹង គាត់ចូលរួមក្នុងឋានៈជាអ្វីដែរ? ឬក៏លោកស្រីមិនដឹងអ្វីទេ?

**ឆ៖** ក្នុងឋានៈជាអ្នកជួយឲ្យយោបល់។

**ស៖** ជាអ្នកជួយឲ្យយោបល់ អ៊ីចឹងលោកស្រីដឹងមកពីណាថា គាត់ទៅចូលរួមប្រជុំហ្នឹង ដើម្បីជួយផ្ដល់ជាយោបល់? វ៉ាន់ រិទ្ធ ជាអ្នកប្រាប់លោកស្រី មែនទេ?

**ឆ៖** មិនមែន វ៉ាន់ រិទ្ធ ទេ គឺគាត់ទៅប្រជុំរាល់ខែជាមួយពួកខ្ញុំហ្នឹងតែម្ដង។

**ស៖** បើអ៊ីចឹងមានន័យថា លោកស្រីជាអ្នកសន្និដ្ឋានដោយខ្លួនឯងទេ មែនទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសុំទោសដែលកាត់ផ្ដាច់ ប្រហែលជាដោយសារការបកប្រែហើយ ប៉ុន្តែសាក្សីបានឆ្លើយហើយ ពេលនោះគាត់មិនដឹងអំពីមុខងារផ្លូវការរបស់គាត់ទេ។ តើលោកស្រីចង់ដឹងអំពីអ្វី? តើចម្លើយដែលអាចឆ្លើយទៅនឹងសំណួរលោកស្រីហ្នឹង អាចឆ្លើយដោយរបៀបណា ព្រោះគាត់ថា គាត់អត់ដឹងតួនាទីផ្លូវការរបស់គាត់ទេនាពេលនោះ។

**កញ្ញា អង់តា ហ៊្គីសសេ៖**

ខ្ញុំព្យាយាមពិនិត្យមើលលម្អិត ខ្ញុំព្យាយាមរំឭកការចងចាំរបស់សាក្សីតែប៉ុណ្ណឹង។ គាត់បាននិយាយថា គាត់ស្មានថា គាត់គិតថា លោក ខៀវ សំផន ហ្នឹងជាអ្នកជួយផ្តល់យោបល់។ អ៊ីចឹងហើយបានជាខ្ញុំព្យាយាមជជីកសួរគាត់ទៅទៀត ដើម្បីឱ្យគាត់នឹកឃើញរឿងរ៉ាវឡើងវិញនោះ។

[១៤:២៦:០៤]

**ស្ទួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកស្រីសាក្សី លោកស្រីឆ្លើយថា វ៉ាន់ រិទ្ធ ជាអ្នករៀបចំកម្មវិធី រៀបចំរបៀបវារៈប្រជុំ ហើយនិងជាអ្នកដឹកនាំកិច្ចប្រជុំ។ ដូច្នេះលោកស្រីអាចជម្រាបបានទេ ថាតើ តាអឿន គាត់មានតួនាទីអីដែរ? ហើយនិង មិត្តថា នោះដែលមានវត្តមានក្នុងពេលប្រជុំហ្នឹងដែរនោះ មិត្តថា គាត់មានតួនាទីអីដែរ?

**លោកស្រី ប៊ិត ហឿន៖**

**ឆ៖** មិត្តថា តួនាទីជាប្រធានមន្ទីរ។ មិត្តអឿន ហ្នឹងមិនមែនប្រុសទេ គឺគាត់ជាស្រីទេ។ គាត់មកជំនួយជាប្រធានផ្នែកដូចខ្ញុំដែរ។

**ស៖** អ៊ីចឹង មិត្តថា ហ្នឹងជាប្រធានផ្ទាល់របស់លោកស្រី និងជាប្រធានផ្ទាល់របស់ អឿន មែនទេ?

**ឆ៖** ចាស។

**ស៖** ក្រោយមកទៀត លោកស្រីបាននិយាយអំពីការចាប់ខ្លួន ឬក៏ការដក តាហុង។ បើខ្ញុំយល់មិនច្រឡំទេ បើខ្ញុំខុស សូមលោកស្រីកែខ្ញុំ គឺថាគាត់ហ្នឹងត្រូវបានគេដកក្រោយពីគេចាប់ខ្លួន សោ ភឹម គឺមានន័យថាគេដក តាហុង ហ្នឹងក្រោយពីគេចាប់ សោ ភឹម ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

[១៤:២៨:០៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ប្រហែលជាដោយសារការបកប្រែទៀតហើយក៏មិនដឹង ប៉ុន្តែសាក្សីនិយាយពី តាហុង ដែលត្រូវបានគេចាប់ខ្លួន ដែលជាប់ពាក់ព័ន្ធទៅនឹង សោ ភឹម។ ខ្ញុំស្តាប់ឮសួរ អឿន តើកំពុងនិយាយពី ហុង ឬក៏យ៉ាងណា? ឬក៏មាន អឿន ណាមកជាប់ពាក់ព័ន្ធដែរនោះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំនិយាយពី តាហុង អត់និយាយពី អឿន ទេ។ សាក្សីនេះ គាត់បាននិយាយថា តាហុង ជាអនុប្រធាន របស់ វ៉ាន់ រិទ្ធ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងលោកស្រីសាក្សី ខ្ញុំចង់សួរលោកស្រីឲ្យបានច្បាស់ តើ តាហុង នេះត្រូវបានគេដកចេញក្រោយពីគេចាប់ខ្លួន សោ ភឹម អ៊ីចឹងមែនទេ? លោកស្រីអាចបញ្ជាក់ត្រង់ចំណុចនេះបានទេ?

**លោកស្រី ប៊ិត ហឿន៖**

**ឆ៖** ចាស។

[១៤:២៩:២៤]

**ស៖** លោកស្រីដឹងដោយរបៀបណាថា សោ ភឹម ត្រូវបានចាប់ខ្លួន? ហើយអ្នកណាជាអ្នក <ប្រាប់លោកស្រី>?

**ឆ៖** ខ្ញុំមិនដឹងដែរ តែគ្រាន់តែដឹងថា គេល្បីថា សោ ភឹម ក្បត់ សោ ភឹម ក្បត់ ដល់នេះ ក្រោយមកគេចាប់ខ្លួន តាហុង ហ្នឹង។

**ស៖** អ៊ីចឹងគឺជាពាក្យចចាមអារ៉ាមទេ អ៊ីចឹងនោះ។ លោកស្រីឮគេនិយាយពីរឿងហ្នឹងនៅពេលណាដែរ លោកស្រីចាំទេ?

**ឆ៖** ឮប្រហែលជាឆ្នាំ៧៨។

**ស៖** លោកស្រីស្ដាប់ឮគេនិយាយហ្នឹង គឺប៉ុន្មានខែ ប៉ុន្មានសប្ដាហ៍ មុនពេលដែលគេចាប់ខ្លួន តាហុង?

**ឆ៖** មិនយូរទេ។

**ស៖** ឥឡូវខ្ញុំសួរបញ្ជាក់ឲ្យច្បាស់។ លោកស្រីចង់មានន័យថា តាហុង ហ្នឹងត្រូវបានគេចាប់ខ្លួនក្រោយពីលោកស្រីឮគេនិយាយពីការចាប់ខ្លួន សោ ភឹម នោះ? ហេតុការណ៍នុ៎ងវាកើតឡើងអាមួយណាមុន មួយណាក្រោយ លោកស្រីអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចបានទេ?

**ឆ៖** បន្ទាប់ៗគ្នា។

**ស៖** ហើយចុះក្រោយមកទៀតនុ៎ង មានរឿងអីកើតឡើង?

**ឆ៖** ក្រោយមកទៀត មិនដឹងមានស្អីគេកើតឡើង មានតែចាប់ពួកប្រពន្ធគាត់ កូនចៅគាត់បន្ត

ហើយដកបន្តៗមកទៀតមក។

[១៤:៣២:១៣]

**ស៖** ខ្ញុំមិនសួរអ៊ីចឹងទេ ខ្ញុំចង់ដឹងថាអ៊ីចេះ តាហុង ហ្នឹងត្រូវបានគេដកហ្នឹងមុន ឬក៏ក្រោយពេលដែលលោកស្រីឮពាក្យចចាមអារ៉ាមពីការចាប់ខ្លួន សោ ភឹម?

**ឆ៖** គឺក្រោយពេលដែលគេចាប់ខ្លួន សោ ភឹម។

**ស៖** ឥឡូវនេះខ្ញុំចង់ត្រឡប់ក្រោយបន្តិច មកនិយាយអំពីពេលដែលលោកស្រីទៅកំពង់ឆ្នាំង។ លោកស្រីបានឆ្លើយជូនអង្គជំនុំជម្រះសាលាដំបូងថាលោកស្រីទទួលខុសត្រូវខាងកសិកម្មនៅកំពង់ឆ្នាំង។ ខ្ញុំចង់ដឹងថា ស្រែដែលលោកស្រីធ្វើការហ្នឹង នៅកន្លែងណាដែរ បើយើងធៀបទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានដែលគេសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង ស្រែហ្នឹងនៅកន្លែងណា?

**ឆ៖** ស្រែហ្នឹងនៅខាង បើយើងពិនិត្យពីភ្នំកងរីមក មានភ្នំកងរីនៅពីខាងស្តាំដៃ ហើយមានទន្លេ។ មានទន្លេហើយ មានវាលមួយសម្រាប់គេធ្វើស្រែប្រាំង។ អាហ្នឹងពីលិចកើត គេហៅកំពង់ឆ្នាំងក្រោមកន្លែងហ្នឹង។ ហើយនៅកន្លែងហ្នឹង ខ្ញុំអត់មានតួនាទីអីទេ។ មេធាវីថា ខ្ញុំមានតួនាទីអី?

**ស៖** លោកស្រីបានឆ្លើយថា លោកស្រីបានឃើញការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។ អ៊ីចឹងខ្ញុំចង់ដឹងឲ្យច្បាស់ថា ស្រែដែលលោកស្រីធ្វើការហ្នឹង មានចម្ងាយប្រហែលជាប៉ុន្មានម៉ែត្រដែរពីព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង? លោកស្រីអាចឆ្លើយប្រហាក់ប្រហែលបានទេ ឧទាហរណ៍ដូចជាថា ជាង១០០ម៉ែត្រ ឬក៏១គីឡូ ឬក៏បើយើងដើរទៅហ្នឹង ប្រហែលជាប៉ុន្មានជំហានពីស្រែហ្នឹងទៅដល់ព្រលានយន្តហោះហ្នឹង?

**ឆ៖** បើយើងដើរពីព្រលានយន្តហោះទៅ ប្រហែលជា៣គីឡូ ហើយនៅជិះទូកឆ្លងទៀត ជិះទូកឆ្លង អាហ្នឹងវែងដែរ ជិះទូកឆ្លង។ ជិះទូកឆ្លងមួយជាន់ទៀត បានដល់។

[១៤:៣៥:៣៧]

**ស៖** ចំណុចចុងក្រោយពាក់ព័ន្ធនឹងបញ្ហានេះ។ ពេលលោកស្រីឃើញមនុស្សធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង គឺថាលោកស្រីមិននៅកន្លែងហ្នឹងទេ មែនទេ? លោកស្រីមិនដែលធ្លាប់ស្នាក់នៅនៅការដ្ឋានសាងសង់ព្រលានយន្តហោះហ្នឹងទេ មែនទេ?

**ឆ៖** ខ្ញុំធ្លាប់នៅយប់ឡើង គឺមកសម្រាន្តហ្នឹង ដល់ព្រឹកបានគេបញ្ជូនទៅធ្វើស្រែប្រាំងហ្នឹង។

**ស៖** ដូច្នេះបើខ្ញុំយល់មិនច្រឡំទេ លោកស្រីមានខ្ទមសម្រាកហ្នឹងគឺថានៅ<មិនឆ្ងាយពីព្រលាន

យន្តហោះហ្នឹងទេ> ក៏ប៉ុន្តែកន្លែងដែលលោកស្រីធ្វើការហ្នឹង គឺ<ផ្សេង>ពីការដ្ឋានសាងសង់ព្រលានយន្តហោះហ្នឹង ត្រឹមត្រូវទេ?

**ឆ៖** ចាស។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ ហើយលោកមេធាវី គង់ សំអុន គាត់អត់មានសំណួរទេ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណលោកស្រី ប៊ិត ហឿន។ សវនាការស្តាប់សក្ខីកម្មលោកស្រីក្នុងឋានៈជាសាក្សី រហូតដល់ពេលនេះដល់ទីបញ្ចប់ហើយ។ ហើយសក្ខីកម្មរបស់លោកស្រីអាចនឹងរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ ហើយលោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ សូមលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។

អង្គជំនុំជម្រះអរគុណលោកស្រីមេធាវី សុក សុជាតា ឥឡូវនេះលោកស្រីអាចសម្រាកបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយសវនាការនៅថ្ងៃនេះ ត្រូវដល់ពេលត្រូវឈប់សម្រាកហើយ ទោះបីនៅសេសសល់ពេលវេលាខ្លះរសៀលនេះក៏ដោយ ដោយថ្ងៃនេះពុំមានសាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីបម្រុងទុកនោះទេ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-897 ហើយនិងអាចមានដើមបណ្តឹងរដ្ឋប្បវេណីបម្រុង 2-TCCP-258 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការ

នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៤:៣៨ នាទី)*